# ការសម្ភាសន៍របស់ បងស្រី ស៊ិនសុខនីន

កៈ អ្នកធ្វើការសម្ភាស់ន៏លន់មុណាក់ ខៈ
អ្នកដែលគេការសម្ភាសន៏ ម៉មសុភា

កៈ ជាដំបូងនាងខ្ញុំសូមជំរាបសួរបងស្រី!
នាងខ្ញុំមកពីខាងសាលាសាកលវិទ្យាល័យប្រូវ៉ូប៊ីបាយយូព្រីហាំយ៉ាងនៃសហរដ្ឋអាមេរិច!
ហើយគេបានអញ្ជើញខ្ញុំមកថ្ងៃនេះដើមប្បីធ្វើការសំម្ភាសន៏បងស្រីខ្លះៗពីប្រវត្តិហើយនិងខ្សែជីវិតរបស់របស់បងស្រីកាលពីកុមារភាព!
ដូចជាតើបងស្រីបានឆ្លងកាត់នៅការលំបាកអ្វីខ្លះ?កាលពីបងនៅក្មេងរហូតមកដល់ឥឡូវនឹង!!! ហើយនឹងពីខ្សែជីវិតនៅជំនាន់សម័យប៉ុលពតដែល។
តើខ្ញុំអាំចធ្វើការសម្ភាសន៏សួរពីប្រវត្តិនៃខ្សែជីវិតរបស់បងស្រីងកាលពីជំនន់នឹងបានទេបង??
ខៈ ចាបាន!! តែខ្ញុំកើតមិនពីសម័យនឹងទេ!! កើតក្រោយ!
តែខ្ញុំបានជួបនូវនឹងអាជីវិតលំបាកនឹងវាច្រើន!ចា!
កៈ ចាបង!!
ខៈ អាជីវិតហត់នឿយហាស់!!?
កៈ ចាចា!! អរគុណច្រើនបង។ អញ្ចឹងនាងខ្ញុំជាអ្នកសម្ភាសន៏ឈ្មោះ លន់មុណាក់ ហើយថ្ងៃនេះជាថ្ងៃទី ១៨ខែ ៥ ឆ្នាំ ២០២០៕ អញ្ចឹងតើបងស្រីមានឈ្មោះអ្វីដែល???
ខៈ ឈ្មោះអ្នកដែលគេធ្វើការសម្ភាសន៏: គឺឈ្មោះបងស្រី: ស៊ិន សុនីន៕
កៈ តើបងស្រីមានឈ្មោះអ្វីដេល???
ខៈ ខ្ញុំឈ្មោះ ស៊ិនសុខនីន!!
កៈ ហើយ! អញ្ចឹងតើបងមានឈ្មោះក្រៅអីផ្សេងពីនឹងទៀតអត់??? ដូចជា!
ដែលគេហៅក្រៅកាលពីនៅក្មេងហាស់!!!
ខៈ ឈ្មោះតែនីននីន!!! គេហៅតែនីននីន!។
កៈ គេហៅឈ្មោះនឹងតាំងពីក្មេងមករហូតអញ្ចឹងតែម្តងឬក៏យ៉ាងម៉េចដែល???
ខៈ ពីក្មេង!!! បើខ្ញុំនៅពីតូចមិញញឪពុកខញ្ញុំហៅខ្ញុំថា!! មីក្អៀកគេហៅមីក្អៀក!
ដែលឪពុកខ្ញុំគាត់ហៅហាស់!។
កៈ ចាបង!!!
ខៈ ពីព្រោះអី!! កាលខ្ញុំនៅពីតូច! ខ្ញុំរាគតែអាចម៏អត់បាត់ទេ!!! ហាហា។
ខ្ញុំទៅជុះពោះផងទៅអីផងជុះតាន់ផង! ជាប់មីក្អៀកៗ!!!
សព្វថ្ងៃអ្នកដែលស្គាល់ខ្ញុំកាលនៅសេរីនឹងហាស់!!
កៈ ចាបង!!
ខៈ ទៅណាហើយមីក្អៀកមីក្អៀកនឹងហូ???
គេអ្នកដែលគេមកពីដៃដែលគេស្គាល់ខ្ញុំហាស់។ គេមកគេសួររកខ្ញុំ!!
កៈ ចាបង!!
ខៈ ទៅណាបាត់ហើយមីក្អៀក គេដែលទឹមតែមកពីថៃ!!
កៈ ចាបង!!
ខៈ ទៅខាងស្រុកប្តីវាបាត់ហើយ៕ ហើយក៏ជាប់មីក្អៀកដល់សព្វថ្ងៃនឹងមកចា!!!
កៈ ក្អៀកឬក៏រាគបង???
ខៈ ក្អៀក!
កៈ ក្អៀក??? អូ!!
ខៈ ក្អៀកគេហៅក្អៀកចា!
ពីព្រោះអីយើងវារាគអាចម៏ដូចកូនងារាគតែអាចម៏ទេ!។
កៈ អញ្ចឹងឪពុករបស់បងក៏ដាក់ឈ្មោះថាអញ្ចឹងទៅ???
ខៈ អញ្ចឹងឪពុកក៏ហៅខ្ញុំមីក្អៀកៗជាប់ េហូតចឹងបាដោយទៅ!!!
តែឈ្មោះរប់ខ្ញុំពិតគឺ!! សុខនីនៗ!អញ្ចឹងហាស់?៕

ក៖ ចាបង!!
ខ៖ ហើយដល់ពេលខ្ញុំមកនៅទីនេះគ្មាននរណាដេងទេ។
ព្រោះអីឈ្មោះខ្ញុំដាក់ថាសុននីន!! តែនៅឯស្រុកខ្ញុំឯណោះគេស្គាល់ទេ!!
ក៖ ចាបង!! ហើយឥឡូវគេស្គាល់តែបងនីនៗទេ?
ខ៖ ចា!!
ក៖ តែបើហៅភ្លៀកទាល់តែទៅ! ស្រុកភូមិកំណើតរបស់បងមែនទេ?
ខ៖ ចា! ហាសហា!
ក៖ ចា! ម៉្យាងដែលបង។
ខ៖ បើទៅនោះយើងគ្រាន់តែឮគេហៅយើងនឹងហើយ។
ក៖ អញ្ចឹងតើបងមានចេះភាសាអ្វីផ្សេងក្រៅពីភាំសាខ្មែរអត់?
ខ៖ អត់!!
ក៖ អត់ទេណោះបង!
ខ៖ ចេះតែខ្មែរ។
ក៖ ចេះតែខ្មែរមួយទេ!?
ខ៖ ចា!
ក៖ បងអត់ដេលបានរៀនភាសាអីផ្សេងទៀតទេណោះ???
ចុះភាសាអង្គគ្លេសបងស្គាល់ខ្លះៗអត់?
ខ៖ ភាសាអង្គគ្លេសកាលខ្ញុំរៀនខ្ញុំចេះខ្លះៗ។ តែដល់ពេលខ្ញុំឈប់រៀន១៥ឆ្នាំផាង!!
ចូលភ្លេចធាតុដើមអស់!។
ក៖ អូ!! កាលនឹងបងឯងចូលរៀនអាយុប៉ុនមាណ?
ខ៖ ខ្ញុំចូលរៀនឈប់ត្រឹមថ្នាក់ទៅ១០។
ក៖ អូ!! កាលណឹងគេមានភាសាអង្គគ្លេសអោយរៀនដែលហីបង?
ខ៖ មានភាសាមាន!! ដោយសាតែយើងអត់សូវមានដួតហាស់!!
អត់មានចំណាប់អារម្មណ៏ទៅអាខាងភាសានឹងហាស់អត់ចេះទេអាភាសានឹងចា។
ក៖ ចាបង!! អញ្ចឹងបងចេះខ្លះ”ដែល?
ខ៖ ពីមុនខ្ញុំ!!! A B អីចេះតែរាប់ទៅណាស់។ ចេះ!! what is your name?
គ្រាន់តែចេះខ្លះ!! តែឥឡូនេះ១៦ឆ្នាំកន្លងផុតទៅខ្ញុំបានភ្លេចវាអស់ហើយ!! ហាហា
ក៖ អញ្ចឹងបានន័យថាបងចេះតែភាសខ្មែរមួយ?
ខ៖ ចា! ខ្ញុំចេះតែភាំសាខ្មែរបច្បាស់ជាំងគេ។
ក៖ អញ្ចឹងចេះតែភាសាខ្មែរនឹង!!
តើបងអាចសរសេរហើយនឹងអានបានស្ទាត់ល្អទេបង?
ខ៖ ចាបាន!! ៩០ ភាគរយ។
ក៖ ៩០ ភាគរយ?
ខ៖ ចា!!
ក៖ អញ្ចឹងតើស្រុកកំណើតរបស់បងកើតនៅភូមិស្រុកណាដែល?
ខ៖ ពីមុនមកហី?
ក៖ ចានឹងហើយពេលកើយហាស់។
ខ៖ កើតនៅភូមិឈើទាល ឃុំឈើទាលស្រុកបាននន់ ខេត្តបាត់ដំបង។
ក៖ ខេត្តបាត់ដំបង?
ខ៖ ចា!!
ក៖ អូខេ!! អញ្ចឹងតើបងឥឡូននឹងមានអាយុប៉ុន្មានហើយ?
ខ៖ ខ្ញុំចូល ៣៨ឆ្នាំហើយឆ្នាំនេះ!
ក៖ ឆ្នាំថ្មី!!
ខ៖ ចា!!
ក៖ អញ្ចឹងតើបងកើតនៅថ្ងៃណាខែណាឆ្នាំណាដែល?
ខ៖ ខ្ញុំកើតនៅឆ្នាំ១៩៩៨២។
ក៖ ចា!! អញ្ចឹងតើបងមានចាំថ្ងៃអត់?ថ្ងៃខែហាស់?

ខៈ ខ្ញុំចាំតែថ្ងៃខ្មែរបុរាណយើងហាស់!!
កៈ នឹងហើយ!!
ខៈ ខែផុជទ្របុទ្យ។
កៈ ខែផុជទ្របុទ្យ?
ខៈ ចា!! ចិតភ្នុំហាស់!!! ខែវេចនៅបាដោយម៉ងហាស់។
កៈ ថ្ងៃទី ១៥ ១៦ ដឹងចឹង?
ខៈ ត្រូវនឹងថ្ងៃច័ន្ទ កើតនៅថ្ងៃច័ន្ទ ខែផុជទ្របុទ្យ ១៩៩៨២!! ឆ្នាំកុល។
កៈ ឆ្នាំកុលហាស់?
ខៈ ចា! អានឹងខ្ញុំចាំច្បាំជាងគេ!!!ហាហា។
កៈ ចុះនៅក្នុងសៀវភៅបញ្ជីជាតិហ្នូ!! គេដាក់អោយនៅថ្ងៃណា?
ខៈ អានឹងទាល់តែមើលនៅក្នុងសៀវភៅគ្រួសារ!! មើលហឺ?
កៈ ចាមិនអីទេបង!!
ខៈ អត់អីទេហី?
កៈ ចា!!
ខៈ អានឹងខ្ញុំអត់ចាំ!! ចាំតែឆ្នាំច្បាស់ជាងគេ។
កៈ ចាបង!! ចាំតែឆ្នាំក៏បានដែល។
ខៈ អញ្ចឹង?
កៈ ចា!! អញ្ចឹងចូលមកដល់អាពាហ៏ពិពាហ៏វិញ!!!
តើបងបានរៀបការនៅខែណាឆ្នាំណាដែលបង?តើបងចាំទេ?
ខៈ ខ្ញុំរៀបការដូចជានៅខែប្រាំនេះ!! ចេញឆ្នាំហាស់!។
កៈ ចាបង!!
ខៈ ចេញឆ្នាំរួច!! ដូចជាចូលឆ្នាំហាស់!!
ចូលឆ្នាំរួចប្រហែលជាដប់ថ្ងៃខ្ញុំរៀបការហាស់។
កៈ ចា!! ចឹងមានតែចុងខែបួន?
ខៈ ចា!! ចុងខេបួននឹងឯង។ តែចូលឆ្នាំវា ២០០៤!!! វា
២០០៤ខ្ញុំបានរៀបការនឹងហាស់។
កៈ ចាបង!!!
ខៈ ចា!!
កៈ អញ្ចឹងតើបងមានចាំថ្ងៃការទេ?
ខៈ ដូចជានៅថ្ងៃអាទិត្យ! ថ្ងៃច័ន្ទ។ ថ្ងៃអាទិត្យថ្ងៃច័ន្ទ។
កៈ ចា! ថ្ងៃអាទិត្យថ្ងៃច័ន្ទ?
ខៈ ចា!! ស្មើរនឹងនឹងថ្ងៃប្រាំបួនកើតដប់កើត!! នឹងខែខ្មែរយើងហាស់។
កៈ ចាបង!!
ខៈ តេបើសិនជាំថ្ងៃទី!! ខ្ញុំអត់ចាំទេ។
កៈ ថ្ងៃទីអត់ចាំទេណ៏បង?
ខៈ ចា!! ថ្ងៃទីប្រាំបួនកើតដប់កើត។ នឹងខែរបស់ខ្មែរយើងហាស់។
កៈ ចាបង!!
ខៈ កាលខ្ញុំការនឹងចូលខែពិសាជ។
កៈ ចូលខែពិសាជ?
ខៈ ចា!! ព្រោះអីយើងចូលឆ្នាំរួចវាដាច់ហាស់ខែពិសាជ!!។
កៈ ចាបង!! អញ្ចឹងតើការរៀបការនឹង!!
តើបានរៀបចំឡើងដោយឪពុលម្តាយអត់?
ខៈ ចាការរៀបការរបស់ខ្ញុំនឹងបានរៀបចំឡើងដោយឪពុកម្តាយទាំងអស់!!
កៈ អញ្ចឹង?
ខៈ ព្រោះអីខ្ញុំនឹងអត់បានស្គាល់គ្នាទាក់ទងនឹងគ្នាទេចា!!
គឺឪពុកម្តាយជាអ្នកផ្សំផ្គុំអោយ។
កៈ អូ!!! ចា!

ខះ ចា!!
កះ អញ្ចឹងបាននៃចា!! អត់ដែលបានទាក់ទងនឹងគ្នាពីមិនមកទេ?
ខះ អត់ដែលបានឃើញទេ!! ខ្ញុំអត់ដែលទៅទាក់ទង។ អត់ដែលទៅស្រឡាញ់!!!
មិនដែលខើញមុខគ្នាសោះ!! ថៃងនឡឪពុកម្ដាយគាត់ជាអ្នកផ្គត់ផ្គង់អោយ។
ជាអ្នកទុកដាក់អោយ។ បើនិយាយអោយចំទៅ!!
កះ ចាបង!!
ខះ ខ្ញុំមិនដែលមាននិស្ស័យជាមួយគាត់ទេ!!!
កះ អញ្ចឹងធ្វើម៉េចបានស្គាល់គ្នាចឹង?
ខះ ពីដំបូង!! គឺអ៊ុំរបស់គាត់នឹងទៅទិញអីវ៉ាន់។ គឺទៅទិញក្រូចអីអញ្ចឹងហាស់!!
កះចាបង!!
ខះ គាត់! ដើរម៉ៅក្រូច! ម៉ៅល្អតទៅក៏ចំផ្ទះរបស់ខ្ញុំនឹង!
ហើយក៏ហូបបាយនៅផ្ទះរបស់ខ្ញុំលេងអញ្ចញចឹងហាស់!! ហើយទៅគាត់ក៏ថា!!
ហុឺចាំអោយក្មួយគាត់មកដឹកពេលល្ងាចឡើយ។
ដោយសារតែក្មួយរបស់ខ្ញុំវាទីមតែមកពីភ្នំពេញ។ និយាយពីរឿនប្ដីខ្ញុំនឹងហាស់!
កះ ចាបង!!
ខះ អោយគេមកដឹងអអីវ៉ាន់អោយ!! ចា!
ហើយទៅយើងទៅតែស្រែចំការបាត់នឹង។ មានទៅមាននិស្ស័យជាមួយណា។
កះ ចាបង!!
ខះ ទៅគាត់ថា!!
ហុឺរកមកតិញកូនជ្រូកនៅស្រុកឈើទាលនេះមួយយកទៅចិញ្ចឹម!!
រកទិញមួយនៅទីនេះមានអ្នកណាគេចិញ្ចឹម?។ ទុកលក់អីអញ្ចឹងហាស់!
កះ ចាបង!!
ខះ ហើយម៉ែរបស់ខ្ញុំគាត់ក៏ថា!! ខ្ញុំមិនដែលចិញ្ចឹងជ្រូកផង។
ហើយម៉ែខ្ញុំគាត់មិនដឹងហាស់។ គាត់និយាយត្រង់!។
កះ ចាបង!!
ខះ ហើយដល់ពេលខ្ញុំមកពីស្រែទៅ!! គាត់ក៏ឃើញខ្ញុំ! ហើយគាត់ក៏សួរម៉ែខ្ញុំ!
ខ្ញុំនឹងត្រូវជាមិច?
កះ ចាបង!!
ខះ ហើយម៉ែរបស់ខ្ញុំគាត់ក៏ប្រាប់ថានឹងត្រូវជាកូនរបស់ខ្ញុំ។
កះ ចាបង!!
ខះ គាត់ក៏ថា!! ហុឺ!! ម៉េចក៏មិនដែលឃើញមកលេងប៉ុនមាណដងហើយ!!
ហុឺបានអីឃើញបើទៅតែស្រែទៅតែចំការបាត់រហូតៗ។ ព្រោះអីដល់ខែច្រូតហូ!!!
កះ ចាបង!!
ខះ ហើយក៏និយាយលេងសើចទៅ!! ហើយយើងក៏ទៅស្រែទៅ។
ហើយដល់ពេលម៉ែរបស់ខ្ញុំគាត់ក៏មិនដែលនិយាយអីដែល។
កះ ចាបង!!
ខះ ដល់ពេលឡើងយូរ!! បូនដប់ថ្ងៃទៅគាត់ក៏ចាប់ផ្ដើមសួរមកខ្ញុំ!។
កះ ចាបង!!
ខះ គាត់ក៏សួរខ្ញុំថាប់សិនជាំគេចង់បានយកគេអត់??? ថាគេនៅណាំនៅណីអី!
គាត់ក៏ប្រាប់យើងមកណា។
កះ ចាបង!!
ខះ ខ្ញុំមិនដឹងទេបើម៉ាក់ឯងខ្ញុំចេះតែយក។ អើ!!
អាញ៉ុំមើលឃើញទៅគេក៏ល្អដែល!។ ហើយបើម៉ែទុកដាក់អោយ!!
ខុសឬក៏ត្រូវអីម៉ែជាអ្នកទទួល។
កះ ចាបង!!
ខះ ម៉ែខ្ញុំគាត់និយាយអញ្ចឹងហាស់។
កះ ចាបង!!

ខៈ ម៉ែអោយកូនម៉ែកិតថាវាល្អសំរាប់ពុកម៉ែ។ បានជាម៉ែហានអោយនឹង។
ម៉ែខ្ញុំគាត់មាននិស្ស័យនឹងគេនឹងហាស់!។
កៈ ចាបង!!
ខៈ ហើយបើខ្ញុំវិញអត់ដែលបានឃើញប្ដីខ្ញុំទេកាលណឹង! អត់ដែលឃើញគ្នាទេ។
កៈ អញ្ជឹងបានជួបតែម៉ាក់ខាងប្រុស?
ខៈ ចានេងហើយ!!
កៈ ហើយដល់ពេលជួបបងទៅគាត់ពេញចិត្តនិងបងហី?
ខៈ ចា!!! ចាឃើញខ្ញុំហើយគាត់ពេញចិត្ត។ ហើយម៉ែពូមីងគេទៅ!!
គេចង់ឃើញខ្ញុំហាស់។
កៈ ចាបង!!
ខៈ កាលណឹងខ្ញុំនឹងវារៀងសដែល!! មិនមែនខ្មៅដូចឥឡូវនេះទេ!!!
កៈ កាលនឹងស្អាត!!!
ខៈ កាលនេងមុខមិនដែលមានស្នាមអីទេ!! មុខឡើងរលោងកាលណឹង។
កៈ ចាបង!!
ខៈ ចុះកាលណឹងយើងអាយុ១៨ ១៩ កាលណឹងអ្នកគ្រូ!!
ចុះកាលណឹងខ្ញុំការនៅអាំយុ ២០។
កៈ ចាបង!!
ខៈ កាលនឹងយើថនៅក្មេង!! ទោះបីជាំយើងនឿយម៉េច។ តែយើងនៅស!!
យើងនេះនៅតែ... ហើយទៅក៏តាមការទុកដាក់របស់ម៉ែឪទៅ!!
ហើយគេក៏គេក៏យល់ពញ្ជរមតាមម៉ែឪមាមីគេនឹងដែលទៅ!។
កៈ ចាបង!!
ខៈ អត់មានទៅបង្ខំអ្នកណាទេ!!
កៈ ចាបង!!
ខៈ នេះរៀងខ្លួនហាស់!!? ចា!
កៈ ចាបង!! អញ្ជឹងពេលជួបគ្នាជួបគ្នាមុនការឬក៏ក្រោយការឬក៏ម៉េច?
ខៈ ជួបគ្នាមុនការ!! ហើយជួបគ្នាមុនការនឹង! ជួបគ្នាបានតែម្ដងគតត់!!!
កៈ ចាបង!!
ខៈ ចា!! ហើយគាត់ក៏ថាហីមិនដែលឃើញកូនក្រមុះកូនកំឡោះ!!
ហើយខាងនេះក៏មិនដែលឃើញ។ ហើយក៏អោយឃើញ!! សូមជួបមុខគ្នាម្ដង។
កៈ ហើយក៏អោយឃើញ?
ខ ចា!! ហើយកាលណឹងខ្ញុំក៏មកពីស្រែវិញរៀងងងឹតៗដែលហាស់កាលនឹង!!
នេះនិយាយការបិតហាស់។
កៈ ចាបង!
ខៈ ដល់ពេលហើយទៅ! ខ្ញុំមកវិញខ្ញុំទទូរជិតហូ!!
ហើយកាលនឹងស្ពាយកាដុងទឹកននៃងននុងចានឆ្នាំងមកពីស្រែកាលនឹងដឹងស្រាប់ហើយ។
កៈ ចាបង!!
ខៈ មកវិញ្ញោឡើងសមៀកស្រម៉កទៅ!!
ហើយទៅប្ដីខ្ញុំគេក៏ចាំអ៊ុំគេឌុបអីវ៉ាន់មកនឹង!!
ក៏គេអត់ពទាំន់ទៅផ្ទះទេតែចាំមើលយើងសិន។
កៈ ចាបង!!
ខៈ ហើយយើងក៏ជំរាបសួរគេអីជម្មតាទៅណាស់។
ហើយគេក៏អត់ប្រាប់យើងថាគេនឹងជានរណាអីដែល!! តែយើងដឹងហើយ។
ព្រោះអីម៉ែគាត់ប្រាប់!!
អោយជួបគ្នានឹងអោយមើលអោយច្បាស់លាស់រៀងខ្លួនទៅ។ កុំអោយថាហី!
ខ្វិនខ្វាក់អីតាណាំចេះតែអោយទៅហើយ។
កៈ ចាបង!!

ខៈ ហើយបានជួបគ្នាតែមួយដងនឹងគត់។ ហើយម៉ែគាត់ក៏ថាមិនអីទេ!!
ហើយាក៏ពេញចិត្ត។ ហើយយើងនឹងក៏ថាចឹងតាមតែម៉ាក់ឯងទៅ។
កើ ចាបថ!!
ខៈ ចុះបើគាត់ថា! គាំត់ពេញចិត្តហើយអោយយើងនេះវាថាម៉េច?។
កៈ ចាបង!!
ខៈ ហើយយយើង! ក៏ចេះតែយលយលទៅ។
តែបើអោយមាននិស្ស័យថាស្រឡាំញ់អីគឺអត់ទេ។ អត់ដែលមនាសោះ!!
កៈ ប៉ុន្តែ!! ដល់ពេលជួបគ្នាទៅបងឯងគិតថារូបសម្បិត្តគេអីយ៉ាងមិចដែល???
ខៈ ចា!! អត់អីទេ! គេ! គេថាអាចទទួកយកបាន។
កៈ ចា!! តែបងឯងដេងតែស្អាតហើយកាលនៅពីក្មេងហូ!!
ខៈ ហាសហា!!
កៈ ប៉ុន្តែពូហូ!???
ខៈ ចានឹងហើយ!!
កៈ ចា! ពេលបងឯងជួបពូ! ម៉េចដែល? គេគ្រាន់បើតើហី?រូបរាងរបស់គាត់អី!!
ខៈ រូបរាងគេអត់អីទេ!! រូបរាងរបស់គេហាស់។
កៈ ចាបង!!
ខៈ តែខាងប្រុសរាងស្គមជាងនេះតិច។ តែសក់របស់គេដូចផ្កាថ្កូវ!។
កៈ ពូគាត់សង្ហារដែលតើហីបង?
ខៈ ចា!! ហើយខ្ញុំថាយីមកពីណា? រាងដុះពុតមាត់តិចៗហាស់។
កៈ ចាបង!!
ខៈ ហើយមីងមាគាត់ក៏ថា!! វាទឹមតែមកពីភ្នំពេញ។
កៈ ចាបង!!
ខៈ អុំរបស់គាត់ថាគាត់ទឹមតែមកពីភ្នំពេញបានពីរបីថ្ងៃ!!
ក្នាមិនទាន់បានកោឯណា។ សូម្បីតែសក់របស់គ្នាឡើងជ្រោង។
កៈ ចាបង!!
ខៈ ហើយយើងក៏នៅស្ងៀមទៅ។ ហើយទៅប្រហែលជាចូលដល់កន្លះខែអីនឹង!!
ក៏ភ្ជាប់ពាក្យភ្ជាប់អីភ្លាមនឹងហាស់ទៅ។ គេថាគេមិនទុកុយូរទេ។
កៈ ចាបង!!
ខៈ ហើយដល់បពេលអញ្ជឹងទៅ!!!
ខ្ញុំភ្ជាប់ពាក្យមិនទាន់បានប៉ុន្មានខែផងនឹងខ្ញុំរៀបការ!!
កៈ ចឹងលឿនផងបង!!
ខៈចា!! ចាស់ៗគាត់អត់ទុកយូរណាកាលនឹងហូ!!
ពួកគាត់ចូលដណ្ដឹងយើងបានពីបីខែ!! ក៏ធ្វើសំបុត្រភ្លាមៗនឹងហាស់។
កៈ ចាបង!!
ខៈ ហើយក៏!! នេះដូចហៅដាក់បាដោយនឹងហាស់!!
មិនដែលមានទំនាក់ទំនងអីជាមួយនឹហគ្នាផងនឹងហា!!
ហើយក៏វាចេះតែសុខដល់សព្វថ្ងៃនេះដែល!។
កៈ នេះដូចជាស្នេហាទំទារ!!
ខៈ ចានេះហេតុតែជាគូររបស់យើងហាស់។
កៈ ចាបង!! តែស្នេហសរបស់ទំទារគេឃើញគ្នាភ្លាមស្រឡាញ់ភ្លាម!
តែយើងកាលណឹងឃើញភ្លាមអត់ស្រឡាញ់ភ្លាមទេបងណោះ?
ខៈ ចានឹងហើយ!! ហើយគាត់បាននិយាយប្រាប់ខ្ញុំដែល!!
គាត់បានទៅរស់នៅភ្នំជា១០ឆ្នាំអីអញ្ជឹងហាស់!! វាមិនអត់មានទេស្រី!!
តែគាត់មិនដែលចាប់អារម្មណ៏ឬក៏ខឹលខូចអីជាមួយអ្នកណាទេ!។
គាត់ខូចតែមាត់ទេគាត់។
កៈ ចាបង!!
ខៈ គាត់គឺបរិសុទ្ធស្អាតបាតណាស់!!!

ក៖ ហូចាបង!!
ខ៖ នេះមែនមិនមែនអីមិនដឹងទេណាស់!!!
ក៖ ចាបង!!
ខ៖ គាត់ថាគាត់អះអាងខ្លួនរបស់គាត់។ គាត់ទៅនៅភ្នំពេញហាស់បួនប្រាំដប់ឆ្នាំ!!
ប្តីខូចតែមាត់ទេ។ ប៉ុន្តែចិត្តមិនដែលមានអោយអ្នកណាទេ!!។
ក៖ ចាបង!!
ខ៖ ហើយអ្នកភូមិគេថា!!! អានីនឯងបានប្តីល្អហើយ។
ដែលមិនចេះមានអ្នកណាហូ!! ហាសហា។
ក៖ ចាបង!! ប៉ុន្តែខ្ញុំធានាថាគាត់ល្អ។
ទោះបីជាសព្វថ្ងៃនេះក៏ដោយក៏គាត់មិនដែលខិលខូចអីដែល!!។
ក៖ ចាបង!!
ខ៖ ចា!! គាត់មិនដែលអោយយើងពិបាកចិត្តនឹងគាត់រឿងចឹងៗហាស់។
ក៖ ចាបង!! ពូគាត់ល្អ។
ខ៖ ចា!! គាត់ល្អ។
គាត់មិនដែលអោយយើងចខ្វល់ខ្វាយជាមួយគាត់នឹងរឿងអាចឹងៗនោះទេ។
ក៖ ចាបង!! ហើយដល់ពេលអញ្ចឹងទៅ!!
ការជួបដំបូងរបស់បងនឹងអត់មានចិត្តស្រឡាញ់លើគ្នាអីបន្តិចបន្តួតទេអីទេអត់
នេះបង?
ខ៖ មិនដឹង!! មិនដែលបើនិយាយទៅ។ នេះដូចជាការចាប់ដាក់យកចឹង។
ខ្ញុំមិនដែលទៅមាននិស្ស័យស្រឡាញ់អីម៉េចផងនឹង។
ក៖ តឡូវចេះ!! ខ្ញុំចង់សួរបងថាពីមុនដែលបងជួបពូនឹងហាស់!!!
មានដែលធ្លាប់ស្រឡាញ់នរណាគេអីដែលទេ?
ខ៖ ចា!! ខ្ញុំធ្លាប់មាន!!! នេះនិយាយការពិតទាំងអស់ហាស់!។
ក៖ ចាបង!!
ខ៖ អ្នកដែលគេនៅចំការជិតគ្នានឹងយើងនឹងហាស់។
គេរកចូលដណ្តឹងយើងដែល។
ក៖ ចាបង!!
ខ៖ គេរកចូលដណ្តឹងយើងនឹង!! តែគេរៀងផឹកបន្តិត។រៀងផឹកបន្តិតតែ
អាយុប្អូនប្តីខ្ញុំតែបន្តិតទេ។
ក៖ ចាបង!!
ខ៖ ហើយកាលនឹងគេអោយខ្ញុំ៥០០០០បាត!!
៥០០០០បាតកាលនឹងថ្លៃណាណាស់!!!
ក៖ ចាបង!!
ខ៖ ហើយកាលនឹង! មាសមួយជីតែ ១៣០០០០ ទេកាលនឹង។ គេអោយយើង
៥០០០០។ ហើយខានស្លាគេអោយយើងប្រាំជីកាលនឹងហាស់!។
ក៖ ចាបង!!
ខ៖ ៥០០០០! ហើយខាន់ស្លាប្រាំជី។ យើងចំការជិតគ្នាយើងវាមាននិស្ស័យហាស់។
ធ្លាប់ទៅមកធ្លាប់ឃើញគ្នាអីអញ្ចឹងហាស់។
ក៖ ចាបង!!
ខ៖ ធ្លាប់ទៅមកធ្លាប់ឃើញគ្នាចឹង! ដល់មាននិស្ស័យអញ្ចឹងទៅ!!
ខ្ញុំក៏មានចិត្តស្រឡាញ់គេខាងណោះដែល។ហើយគេក៏ស្រឡាញ់យើងវិញដែល។
ដូចដឹងចិត្តចឹងហាស់!! ចុះធ្លាប់តែទៅមកខើញគ្នាចឹងហាស់។ តែមួយនោះ(
ប្តីរបស់គាត់ ) ខ្ញុំអត់ដែលបានខើញអញ្ចឹងមិនដែលមានចិត្តទៅស្រលាញ់អីណា។
ក៖ ចាបង!!
ខ៖ តែម៉ែរបស់ខ្ញុំគាត់អត់ពេញចិត្តនឹងម្នាក់ដែលខ្ញុំស្រឡាញ់នឹងទេ!!
គាត់ថាអានឹងវាផឹកកាត់ទៅរកៀឱរបស់វា។

ទៅស្រឡាញ់អីអាមនុស្សប្រមឹកងញ៉ឹងនោះ!! ម៉ែខ្ញុំគាត់ថាទោះបីជាខ្ញុំស្រឡាញ់!!
ហើយក្នាក់នឹងគេចូលដណ្តឹងខ្ញុំក៏គាត់មិនអោយគេដែល!!។
កៈ ចាបង!!
ខៈ ហើយព្រោះអីគេចូលមកសួរខ្ញុំនឹងវាពីរដងហើយ។
កៈ ចាបង!!
ខៈ ហើយទៅមិនដឹងដឹងមកពីនាក់ណា?!!
ម៉ែខ្ញុំគាត់ទៅមើលហោហាស់ហោទៅគាត់ល្បីហាស់។ ដល់ពេលទៅមើលហោទៅ!!
ផ្ទះរបស់អាប្រុស( ខាងប្រុស ) នឹងគាត់នៅជិតនឹង។
កៈ ចាបង!!
ខៈ អញ្ចឹងទៅគាត់ក៏ថា!! ហឺ!! ឮសួរមានអ្នកណាចង់បាន។
ពេកគេចង់ចូលដណ្តឹងអោយគេភ្លាម។ ផ្តាច់ពាក្យពីខាងនេះផ្តាត់នេះភ្លាម៕
បើគេអោយលើសអីគាត់គិចមិនបានទេ!!!
កៈ ចាបង!!
ខៈ ហើយម៉ែរបស់ខ្ញុំគាំត់ក៏ថា!!! កូនវារាប់អានគ្នា។អ្នកចំការអីចឹងហាស់។
កៈ ចាបង!!
ខៈ ចា!! ដល់ពេលហើយទៅម៉ែខ្ញុំគាត់ក៏ថា!! ស្គាល់គ្នាជាមួយអ្នកអូដំបង!! ហើយ
រាប់អានគ្នាជាំចាស់ជាទុំ។ ដល់ពេលអញ្ចឹងទៅគាត់ក៏ថា!!!
ហុីប្រយ័ត្នតើមិនត្រូវនឹហគេណោះហាស់។
តើអោយអ្នកនេះទៅចូលដណ្តឹងមមិនអោយមិនអីទេណាស់។ខ្ញុំមិនអោុយកទេ
ណាស់!! មិនអោយកូនប្រុសខ្ញុំយកទេណាស់។
គាត់និយាយភាសាដាក់ខ្ញុំអញ្ចឹងហាស់។
កៈ ចាបង!!
ខៈ ខ្ញុំនឹកឃើញអាពាក្យដែលគាត់បាននិយាយដាក់ខ្ញុំអញ្ចឹងហាស់។
កៈ ចាបង!!
ខៈ ខ្ញុំតូចចិត្តនឹងខ្លួនឯង!! ហឺ!! ខ្លួនឯងដូចអន់ដូចទំនិញឬក៏មិច?។
កៈ ចាបង!!
ខៈ ដល់ពេលគាត់និាយយាភសាថាចឹង!
ប្រយ័ត្នអ្នកនោះមិនត្រូវមកអោយកូនខ្ញុំឯនេះទៅចូលសណ្តឹងមិនអោយទៅយក
ទៀតទេ។
កៈ ចាបង!!
ខៈ ដល់ពេលខ្ញុំឮពាក្យគាត់និយាយដាក់យើងចឹង!! យើងក៏ចង់ឈ្នះគាត់។
កៈ ចាបង!!
ខៈ ហឺ!! ទៅស្រឡាញ់គេធ្វើអីទៀតបើម៉ែគេនិយាយដាក់យើងចឹងហើយ។
ចង់និាយយាភាសាអញ្ចឹងដាក់យើង!
បើសិនជាគាត់ស្រឡាំញ់យើងគាត់ដែលទៅនិយាយភាសាចឹងដាក់យើងហះ?
កៈ ចាបងឯងចិត្តដាច់ដែលកាលណឹង?
ខៈ ចា!! ខ្ញុំនឹកឃើញត្រង់នឹងហាស់។
ហើយខ្ញុំក៏តាមម៉ែរបស់ខ្ញុំត្រង់ពាក្យគេនិយាយចឹងឯង!! កុំអីខ្ញុំអត់នេះទេ។
កៈ ចាបង!!
ខៈ តែយើងស្គាល់គ្នាមកបានពីរបីឆ្នាំចឹងមកហាស់!!!
កៈ ចាបង!!
ខៈ ក៏ដូចជាការទាក់ទងអីចម្មតា! ក៏ឃើញទៅក៏ស្រឡាញ់ទៅ។
មិនបានទៅរ៉ៀវរ៉ៅអីទេ!!
កៈ រ៉ៀវរ៉ៅះអីទេ?
ខៈ ចា!! ព្រោះអីខ្ញុំទៅចំការខ្ញុំមិនដែលទៅតាឯងអីទេ។
ខ្ញុំតែងតែទៅជាមួយម៉ែរបស់ខ្ញុំបប្អូនខ្ញុំទៅចំការនឹង។
កៈ ចាបង!!!

ខ៖ ទៅចំការមើលគោមើលអីហាស់!!
ក៖ ចាបង!!
ខ៖ ហើយក៏មិនដែលខើញមុខគ្នាដែលណាស់៕
តែដល់ពេលយើងមាននិស្ស័យស្រឡាញ់គ្នា។
ក៖ ចាបង!!
ខ៖ ដល់ពេលគាត់និយាយពាក្យនឹងនមកទៅ!! ដឹងឮថាអ្នកនេះចង់បានទៅ! គេមកពីអូដំបងអីអញ្ចឹងហាស់!! ទឹមតែឮថាស្គាល់គ្នាអីបានតែប៉ុន្មានថ្ងៃ។ ឮតែគេចង់បាននឹង! បាច់កូនគេឯណេះ។
ក៖ ចាបង!!
ខ៖ គេអោយលើសគាក់តិច!! ៥,0000 ខ្ញុំក៏ហានអោយដែល។ ៥,0000 ដូចតែគ្នា។ គាត់ថាអញ្ចឹងហាស់!!!
ក៖ ចាបង!!
ខ៖ តែឪវាគេអោយខ្ញុំ! ៥,0000 មែន! តែខាន់ស្លាគាត់អោយខ្ញុំតែបីជីទេ។
ក៖ ចាបង!!
ខ៖ តែខាងណោះវិញ!! គេអោយ ៥,0000 ដូចគ្នាមែន។
តែខាន់ស្លាគេអោយប្រាំជី។
ក៖ បង!!
ខ៖
តែម៉ែរបស់ខ្ញុំគាត់មាននិស្ស័យជាមួយអ្នកខាងណោះផាង៕មើលទៅអ្នកខាងណោះគេល្អហាស់!!!
ក៖ ចាបង!!
ខ៖ គេមិនចេះផឹកស្រា!! ហើយយើងក៏តាមគាត់ទៅ៕
ហើយវាបានដូចបំណងដែល!!! មិនដែលថាអោយយើងពិបាកចិត្តពីបាកអីទេ។ ចេះតែសុខមករហូតទៅ។
ក៖ ចាបង!! គូរយើងណ៏បងមែនហះ???
ខ៖ ចាគូរយើង!! ថាបើគូរព្រេងរបស់យើង!!
ទោះថាមិនដែលទាក់ទងមិចឬជួបមិចក៏ត្រូវតែជួប។
ក៖ ចាបង!!
ខ៖ ចុះយើងមិនដែលបានទាក់ទងគ្នាមកឯណាតាំងពីដើមមក!!។
ដល់ពេលមកជួបពីប! អាប៉ុន្មានខែនឹងដូចជាហួសហេតុម៉ងនឹងហាស់អ្នកគ្រូ។
ក៖ ចាបង!!
ខ៖ ដល់ពេលមកដល់សព្វនេះហាអ្នកគ្រូ!! វាដូចថាធម្មតា។
បើថាស្រឡាញ់មានអនុស្សាវរីយ៍កំសត់អីអត់មានទេ!!
ក៖ ចាបង!!
ខ៖ មែនទេអ្នកគ្រូ??? អត់មានទេ!!! ដូចថាចាប់ដាក់យលបាដោយម៉ងហាស់៕ ចា! ហើយឪវា( បប្តីរបស់គាត់ ) ក៏អញ្ចឹងដែល។
ក៖ ចាបង!! ដូចសម័យប៉ុលពតដែលបង! បើនិយាយទៅ។ ដូចម៉ាក់...។
ខ៖ ចានឹងហើយ!!
ក៖ តែនៅសម័យប៉ុលគេជាអ្នករៀបចំអោយ!!
តែនេះឪពុកម្តាយរបស់យើងជាអ្នករៀបចំអោយ។
ខ៖ ចា!! ដោយឪពុកម្តាយរបស់យើង។
ក៖ ហើយអត់ដែលស្គាល់គ្នាទេណ៏បង?
ខ៖ ចា!! អត់ដែលស្គាល់គ្នាទេ!!
ក៖ អញ្ចឹងដល់ពេលរៀបការទៅ!
ហើយចឹងពេលណាដែលដែលថាបងបាក់ចិត្តស្រឡាញ់លលើពូ?
ខ៖ ជាប្តីប្រពន្ធ! ដូចថាយើងដូចថាវាជាទំល្លាប់ហាស់។
ក៖ ចាបង!!

ខៈ បើភ្លាមៗយើងគ្មាននិស្ស័យទេ។
កៈ អត់ស្រឡាញ់ទេ?
ខៈ ចា!! ហើយថាអត់មាននិស្ស័យថាដែលស្រឡាញ់អីទេ!!
ទឹមតែមាននៅពេលដែលមានកំណើតកូនខ្ញុំមិលីសានែក។
យើងទំនួនកើតកូនលីសានេះហើយហាស់!!!
កៈ ចាបង!!
ខៈ ទើកយើងចេះតែគិតទៅណាស់។
កៈ ចាបង!!
ខៈ ហើយនៅពេលដែលខ្ញុំបានរៀបការជាមួយនឹងគាត់រួចហើយនេះហាស់។
ខ្ញុំចេះតែគិត។ ខ្ញុំចេះតែនឹកឃើញ!! ហី!!
យើងចេះតែរៀបការរៀបការតាឪពុកម្តាយយើងយកទាំងអត់មានចិត្តស្រឡាញ់
ហាស់!!!
កៈ ចាបង!!
ខៈ តែខាងគេ (ប្តីរបស់គាត់ ) គាត់ស្រឡាញ់ខ្ញុំហើយ។
កៈ ចាបង!!
ខៈ តែខ្ញុំអត់ទាន់មានចិត្តស្រឡាញ់គេទេ!!!
កៈ ចាបង!!
ខៈ មែនតើអ្នកគ្រូ!! ខ្ញុំនិាយយាតាមត្រង់។
កៈ ចាបង!!
ដល់ពេលមានកូនមួយនេះទៅ។ លីសាកើតទៅ!!
គាត់ជួយមើលថៃយើងដែលហាស់។
កៈ ចាបង!!
ខៈ យើងដូចថា! រៀងស្រណោះគាត់ខ្លះដែល។ ឃើញគាត់ខំធ្វើការហាស់។
កៈ ចាបង!!
ខៈ ចិត្តគេគេល្អជាមួយយើង។ យើងនឹកឃើញថា!! យើងបានគ្នាជាប្តីប្រពន្ធ!
មានកូនក៏នឹកឃើញចឹង។ ក៏តាមដល់សព្វថ្ងៃនឹងទៅ។
កៈ ចាបង!! ក៏ស្រឡាញ់គ្នាទៅណ៍បង?
ខៈ ចា!! តែបើថាទឹកចិត្តស្រឡាញ់!! តែមិនអោយបាក់ខ្លាំងទេ។
កៈ ធ្មមតាៗហីបង?
ខៈ ចា!! ធម្មតាៗដូចសព្វថ្ងៃនេះដែលបឹងអ្នកគ្រូ។
កៈ ចាបង!!
ខៈ ដូចខ្ញុំអញ្ជឹង!!ចង់ទៅណាទៅទៅ។ គាត់មិនសូវនិយាយទេ។
កៈ ចាបង!!!
ខៈ ហើយគាត់ក៏អញ្ចឹង៕ ទៅណាទៅទៅ!! ខ្ញុំមិនសូវនិយាយទេ។ វាធ្មមតាចឹងហា។
មិនសូវនិយាយទេ!!!
កៈ ចាបង!!
ខៈ ដោយសាតែនេះសំម្រេចឃោយដាស់ទុំ។ អត់មានចិត្តស្រឡាញ់អីខ្លួនឯង!
គឺអត់មានទេ
កៈ ចាបង!ម្យ៉ាងដែល!
ខៈ ចា!!  នេះចាប់យកបាដោយ។ អត់ដែលបានឃើញមុខផង។
កៈ ចាបង!! នេះបើអត់សួរបងអត់ដឹងទេ។
ខៈ ចា!!នជរឿងពិតវាចឹងឯង។
កៈ ចាបង!!
ខៈ ចា!! ហើយពេលដែលខ្ញុំ។ ខឹងអីខឹងទៅ! ខ្ញុំចេះតែថា!!
ហុ៎ខ្ញុំមិនគួរណាយលឯងសោះហាស់។
កៈ ចាបង!!

ខ៖ ហើយគាត់ក៏ថា!!
ហើយចុះអ្នកឯងយលខ្ញុំនឹងបើដឹងថាគល់ឈើហើយចេះតែយលដែលចុះ???
គាត់ថាអោយខ្ញុំហាស់។
ក៖ ចាបង!!
ខ៖ គាត់ថាអោយខ្ញុំចេះចុះ។ ចុះបើដឹងអញ្ជឹងតាំងពីដើមឯងមិចមិនប្រកែក!!!
ឯងមកយកខ្ញុំធ្វើអី??? ហើយយកតាមគាត់ធ្វើអីបើយើងមិនស្រឡាញ់?
ក៖ ចាបង!!
ខ៖ ហើយខ្ញុំក៏ថា!! ហុ៎! ខ្ញុំខ្លាចម៉ែខ្ញុំគាត់ខូចចិត្ត!!!
ក៖ ចា! ខ្លាចម៉ែខូចចិត្ត!
ខ៖ ចា!! នៅពេលដែលយើងចឹងយើងចេះតែថាទៅណាស់!!!
ក៖ ចាបង!!
ខ៖ ចាអ្នកគ្រូ!! ជីវិតប្តីប្រពន្ធ! វាគិចមិនផុតទេពីការឈ្លោះគ្នាហាស់!!!
ក៖ ចា! ត្រូវបង!!
ខ៖ ចេះតែមាន! ដូចថាចាននៅក្នុងរាវ។ វាចេះតែមានរណ្តំហើយ!!
បើមិនមានរឿងនេះទេរឿងនោះ។
ក៖ ចាបង!!
ខ៖ ចា!! វាគិចមិនផុតទេ!! ហើយប្តីខ្ញុំគាត់មិនសូវទេ។ ខ្លាំងជាងគេនឹងគឺខ្ញុំ។
ក៖ ចាបង!!
ខ៖ បើខ្ញុំខឹងខ្ញុំមនចេះទប់ទេ។ ពេលដេលខ្ញុំខឹង!! ខ្ញុំនិយាយប្រាវៗ!!!
តាហើយហើយហើយ៕ តើនិយាយរួចហើយរូចហើយ។ ហើយបើបាននិយាយហើយ!!
កាត់ខ្ញុំនឹងទប់អត់ឈ្នោះទេ៕
ក៖ ចាបង!!
ខ៖ ដូចថាក្តៅនៅក្នុងចិត្តចឹងហាស់។
នៅពេលដែលខ្ញុំបាននិយាយខ្ញុំជបានធូរនៅក្នុងចិត្ត។
ក៖ ចាបង!!
ខ៖ ចា! វាចឹង។ បើថាប្តីខ្ញុំគាត់មិនសូវប៉ុន្មានទេ។
ក៖ ចាបង! អញ្ជឹងអាពាហ៍ពិពាហ៍! ត្រូវបានរៀបបំឡើងដោយឪពុកម្តាយ។
ហើយមានបណ្តាការអីត្រឹមត្រូវទាំងអស់ណ៎បង?
ខ៖ ចា! ត្រឹមត្រូវទាំងអស់។
ក៖ ចាចឹងល្អមេនទែនបង។ គ្រាន់តែថា!
កូនកំលោះកូនក្រមុំអត់បានស្រឡាញ់គ្នាអីទេ!!!
ខ៖ ចា!! អត់បានទាក់ទងស្រឡាញ់គ្នាអីតែប៉ុននឹងឯង។
ក៖ ចាបង!!
ខ៖ អ្នកខ្លះគេបានទាក់ទង!! ដល់ពេលយើងវិញវាត្រឹមត្រូវពេកចឹងហាស់។
ក៖ ចាបង!! បើនិយាយទៅ!
វាជាប្រពៃណៃទំនៀមទំលាប់រនស់ខ្មែរយើងកាលពីជំនាន់នឹហផងណ៎បង?
ខ៖ ចា!! ហើយម៉ែខ្ញុំគាត់រៀងអ្នកបុរាណផងកាលនឹង!
និយាយទៅគាត់បុរាណចំបាដោយនឹងហាស់។
ដល់សពម្វថ្ងៃនេះក៏នៅតែអញ្ជឹងដែល។
សូម្បីតែប្អូនរបស់ខ្ញុំអីនឹងដើរលេងសព្វថ្ងៃអីនឹងខ្ញុំថាអោយដែលនឹង។
ក៖ ចាបង!!
ខ៖ ខ្ញុំថា!! កុំហួងហែងគេពេកពេក!! សម័យនេះហើយ។
អោយគេដើរលេងដើរអីខ្លះទៅ។
ក៖ ចាបង!!
ខ៖ ម៉ែរបស់ខ្ញុំគាត់នៅបុរាណ!! គិចថាឃើញស្លៀកខ្លីស្លៀកអីអត់បានទេណាស់។
ក៖ ស្លៀកខ្លីអត់បាន?

ខៈ ចា!! ខ្ញុំថាអោយគាត់!!
ម៉ាក់ឯងមិនមែនបុរាណជិះសេះទេណាដែលស្លៀកខ្លីមិនបាន។
ខ្ញុំថាអោយគាត់ចឹង។
កៈ ចាបង!!
ខៈ សព្វថ្ងៃនេះ!! រៀងបាដោយខ្លះ។ មិនមែនកូនទេ! គឺក្មួយ។
កៈ ចាបង!!
ខៈ ហើយគេជាអ្នកធ្វើខ្លួន។ គេធ្វើអីធ្វើទៅ។ អោយតែគេគិតថាសម។
កៈ ចាបង!!
ខៈ ខ្លួនគេទេ!!! យើងកុំទៅហួងហែងគេ!!
កុំអោយតែគេទៅខូចអីធ្ងន់ធ្ងរនឹងបានយើងពិបាក។
នេះគ្រាន់តែគេស្លៀកពាក់អីផ្ទុមតារូបកាយគេតើអាណឹង។
កៈ ចាបង!!
ខៈ វាដឹងខ្លួនវាតើ។ អាក្រក់ល្អអី។
កៈ ចាបង!! អញ្ចឹងបើនិយាយដល់គ្រួសាររបស់បងវិញ។
តើបងមានបងប្អូនប៉ុន្មាននាក់???
ខៈ គ្រួសារខ្ញុំមានបីនាក់!! ស្រីពីរនាក់ប្រុសមួយប្រុសពៅ។
កៈ ចាបង!!
ខៈ ចា!!
កៈ ហើយចុះតើបងជាកូនទីប៉ុន្មាន?
ខៈ ខ្ញុំជាកូនទីពីរ!!
កៈ កូនទីពីរ!!
អញ្ចឹងតើបងប្អូនរបស់សព្វថ្ងៃនឹងតើពួកគាត់មានគ្រុមគ្រួសារអស់ហើយ???
ខៈ ចាមានអស់ហើយ!! អាប្អូនប្រុសពៅខ្ញុំនឹង! មានកូនពីរ។
កៈ ចាបង!!
ខៈ កូនពីរ!! ហើយស្រីទាំងពីរ។បងរបស់ខ្ញុំមានកូនប្រាំ!!
កៈ ចាបង!!
ខៈ ស្រីពៅ! តែប្រុសបូន! ប៉ុន្តែអាយុ។ ១៨ ២០ អីះស់ហើយ។
កៈចាបង!!
ខៈ ក្មួយខ្ញុំនឹងហាស់!! ពួកវាធំៗអស់ហើយ។ ជ្រោងៗដូចតមពាំងចឹង។
កៈ ចាបង!!
ខៈ កូនគាត់ប្រាំ។
កៈ ហើយបងឯងកូនពីរ?
ខៈ ចា!!
កៈ បងឯងមមានកូនតិចដែល!! មានកូនតែពីរ!!!
ខៈ ចា!! យលតែប៉ុននឹង។
កៈ បងអត់ចង់បានច្រើនទេបង?
ខៈ អត់!! ឈប់អោយមាន។
កៈ វាបង!!
ខៈ ចិញ្ចឹមកូនមិនរស់ទេអ្នកគ្រូអើយបើកូនច្រើនហូ!!!
កៈ ចាបង!!
ខៈ យ៉ាប់ណាស់!! យ៉ាប់អាយើងវាក្រហាស់។ យ៉ាប់!!!
កៈ ចាបង!!
ខៈ វាយ៉ាប់ចិញ្ចឹម។ បើកូនពីរបីងវាកើតកើតហើយ។
កៈ ចាបង!! ចាអញ្ចឹងស្រួលដែល។ ដែលបងប្អូនមានគ្រុមគ្រួសារអស់ហើយ។
ហើយតើពួកគាត់ទាំងអស់នៅស្រុកខ្មែរទាំងអស់គ្នាតើហីបង?
ខៈ ចានៅស្រុកខ្មែរទាំងអស់គ្នា!!
កៈ ចា!!!

ខៈ មួយនៅខាងឈើទាលចឹងហាស់។
ហើយមួយទៀតបានប្រពន្ធនៅស្វាយស៊ីសំផុនហ្វូ!។
កៈ ចាបង!! ចឹងនៅឈើទាលមួយ! នៅស្វាយមួយ?
ខៈ ចា!!
កៈ ហើយនៅបាត់ដំបងមួយ។ បងឯង?
ខៈ ចា! ចាខ្ញុំនឹងចា!។
កៈ ចា!! អញ្ចឹងតើបងឯងមានបងប្អូននៅស្រុកក្រៅអីអត់ ( នៅបរទេស )?
ខៈ មាន!! មានអ៊ុំជីដូនមួយ! អ៊ុំបង្កើត។ នៅសហរដ្ឋអាមេរិចហាស់!!!
កៈ ចាបង!!
ខៈ តែពួកគាត់នៅរដ្ឋកាលីហ្វូញ៉ា។ តែពួកគាត់ធ្វើការធ្វើពេទ្យហាស់!!!
កៈ ចាបង!! ហើយពួកគាត់បានទៅនៅនឹង!
ពួកតើពួកគាត់បានទៅនៅដោយសារអីដែល?
ខៈ អ៊ុំខ្ញុំពីសម័យប៉ុលពត!! សម័យប៉ុលពតគាត់រត់ទៅ។ ដល់ពេលកូន!
ទៅកើតនៅស្រុកណោះ។
កៈ ចាបង!!
ខៈ ចា!! ហើយគាត់ធ្លាប់មកលេងបានពីដង។
តាំងពីគាត់រត់ទៅនៅសម័យប៉ុលពតហាស់?
កៈ ចាបង!!
ខៈ មកលេងបានពីដង។ អើដូចថសស្រុកគេមែន។
បងប្អូនដូចថាមិនសូវមាននិស្ស័យហាស់។
កៈ ចាបង!!
ខៈ គេមិនសូវបានមក! គេរវល់ធ្វើការ។ ហើយពួវាមិនចភាសាយើងផងនឹងហ្វូ!!
កៈ ចាបង!! ពិបាកទាក់ទងគ្នាហើយចឹង។
ខៈ ចា!!វាមកលេងម្តង។ មិនដឹងថាវានិយាយស្អីផងនឹង!!! ស្តាប់អត់បាន។
ហើយណាមួយយយើងក្រផង!! យើងក៏មិនសូវកហានជាមួយគេ។
កៈ ចាបង!!
ខៈ ហើយខ្ញុំដឹងស្រាប់ហើយ។ ខ្ញុំមិនមេនជាអ្នកដែលអែបអបអីទេ៕
កៈ ចាបង!!
ខៈ តែបើថា!! បើមានការអីចឹង! ខ្ញុំចេះតែនិយាយទៅណាស់។ បើអ៊ុំរបស់ខ្ញុំ!
ខ្ញុំបាននិយាយេជាមួយគាត់ញឹកញាប់ដែល។ តែបើបងប្អូនខ្ញុំវិញ!! ខ្ញុំមិនសូវទេ។
តែបើគេខលមកខ្ញុំនិយាយ។
កៈ ចាបង!!
ខៈ ទាល់តែគេខលមកខ្ញុំបានខ្ញុំនិយាយ!!!
តែបើយើងមានការណ៍ខលទៅរកគេខ្ញុំមិនហានទេយើងខ្លាចគេហាស់!!!
កៈ ចាបង!! ត្រូវហើយបង។
ខៈ ចា!!!
កៈ អញ្ចឹងតើបងឯងមានចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្តាយបងអត់?
ខៈ អត់ចាំទេ!!!
កៈ អត់ទេនបង? ចុះបងមានចាំឈ្មោះរបស់ពួកគាត់អត់ចឹង???
ប្រកត់ជាចាំឈ្មោះពួកគាត់ហហើយមែនទេ?
ខៈ ចាឈ្មោះខ្ញុំចាំ។
កៈ អញ្ចឹងតើពួកគាត់មានឈ្មោះអីដែលបង??? ឪពុកម្តាយរបស់បងហាស់???
ខៈ តារបស់ខ្ញុំគាត់ឈ្មោះឈូ! ដល់ពេលឪពុកខ្ញុំមក គាត់ឈ្មោះឈូស៊ន។
នឹងឪពុកខ្ញុំបង្កើតហាស់៕
កៈ ចាបង!!!
ខៈ ឪពុករបស់គាត់ឈ្មោះឈូហើយ។ ហើយគាត់ឈូស៊ន! ហើយយាយរបស់ខ្ញុំ
យាយយ៉ន! យាយយឹប! ចា!

កៈ យាយ៉ន យាយយឹប។ នឹងជាឪពុលម្តាយរបស់បងឬក៏យាយតារបស់បង?
ខៈ នឹងយាយ! ត្រូវជាយាយ។ យាយតាខាងពុក។ ត្រូវម៉ែ។
កៈ ខាងម្តាយបង?
ខៈ ចា! ខាងម្តាយ!!! នឹងផពុកម្តាយខាងឪពុលខ្ញុំហាស់។
កៈ ចាបង!!
ខៈ នឹងអញ្ចឹងឯង។
កៈ ចុះឪពុកម្តាយបង្កើតរបស់បងវិញ?
ខៈ ឪពុកខ្ញុំឈ្មោះ ឈូស៊ិន!។
កៈ ឈូស៊ិន។
ខៈ នៅរស់!! ហើយម្តាយរបស់ខ្ញុំគាត់ស្លាប់បាត់ហើយ!! គាត់ឈ្មោះស៊ិនទូច!
គាត់ស្លប់បត់ហើយ។ គាត់ស្លាប់នៅអាយុ ៤៥។
កៈ ៤៥??? អូគាត់នៅក្មេងមែនទែន!
ខៈ គាត់ស្លាប់ដោយសារកើតជំងឺតឹកនោមប្រៃ។
កៈ ទឹមនោមប្រៃ...។
ខៈ គ្រួសារខ្ញុំបើនៅបួននាក់!! កូនងាកើតបានប្រហែលជាកន្លះខែ!! ស្រីទៀត។
តឹកនោមប្រៃដល់ពេលកើតទៅប្រកាច់។ នៅពេទ្យហាស់!!!
កៈ ចាបង!!
ខៈ ហើយខ្ញុំមានអាយុប្រហែលជាប្រាំមួយឆ្នាំ។
ហើយគាត់ដឹកយកទៅនៅពេទ្យធំយើងនែក។
កៈ ចាបង!!
ខៈ ហើយឡានគេដឹកយកទៅ។ដៃរបស់គាត់ហើម!!
ហើយដៃហើមជើងប្រកាច់លានអណ្តាត។
កៈ អូ!!! ចាបង។
ខៈ ហើយគាត់ប្រឹងទៅ!! ហើយយើងសសៃខ្ចីដឹងស្រាប់ហើយអ្នកគ្រូ។
កៈ ចាបង!!
ខៈ អញ្ចឹងទៅ។ ហើយចឹងទៅគាត់ហើមដៃ!
ហើមជើងពេទ្យគេដឹកមកដាក់នៅមុខផ្ទះទៅ។
ហើយកាលសម័យនឹងយើងមិនច្រើនធ្វើបុណ្យនៅវត្ត!! យើងអត់ធ្វើនៅនឹងផ្ទះទេ។
ធ្វើបុណ្យនៅវត្តឈើទាលនឹង។ ហើយកូនងារទុកនៅនឹហផ្ទះទៅ។
អោយបៅទឹកដោះគោ។ អោយបៅទឹកដៅគោ!! បានប្រហែលជាកន្លះខែ។
ពីរអាទិត្យទៅកូននឹងស្លាប់បាត់។
កៈ អូ!!! មិចបានចឹងបង?
ខៈ វាអត់រស់!
កៈ កូននឹងខ្សោយឬក៨មិចបង?
ខៈ កូននឹងអត់ខ្សោយទេ។ វាអត់រស់។វាកើតមកសុខភាពល្អ។
ធាត់មួលឡើងត្រឡញ។ សសក់ដូចបារាំង។
កៈ ហើយម៉េចបានជាកូននឹងងាប់ចឹង?
ខៈ វាមិនដឹងថាមូលហេតុអីដែល។ កូននឹងកើតបានពីអាទិត្យ។
កៈ ហឺ!!!
ខៈ អានឹងកូនងារ!!! កាលនឹងយកមកទុកជាមួយខ្ញុំ! ខ្ញុំនៅតូច។
តូចជាងមីលីសាទៀត។
កៈ កូនណឹងត្រូវជាប្អូនបងឯងមែន?
ខៈ ចា!!!ប្អូនខ្ញុំបង្កើត បងប្អុនខ្ញុំត្រូវបួននាក់ហាស់។
កៈ ស្តាយមែនតែនបង។
ខៈ ហ៊ឺបើនៅ!! វាក្រោប្អូនបន្តិចនឹងឯង។ មែនមិនមេនអ្នកគ្រូ?
កៈ ចានឹងហើយបង!!
ខៈ ចាប្អូនខ្ញុំពីរបីឆ្នាំអីនឹងឯង!!! បើរនៅស្រកអ្នកគ្រូឯងអីនឹងឯង។

កៈ ចាបង! ស្តាយគាត់មែនទែន។
ខៈ ចាស្រី។ សឡើសុះ! សក់ឡើងក្រហាម។ច្រមុះឡើងស្រួច។
កៈ ចាបង!!
ខៈ មាបងប្អូនខ្ញុំទាំងអស់សុទ្ធតែស្អាតៗ!!! អាក្រក់តែខ្ញុំមួយ។
កៈ ចាបង!!ដូចញ្ញមដែល។
ខៈ បងប្អូនពួកគាត់ខ្ពស់ហាស់។ចុះម៉ែខ្ញុំគាត់លិវ។
កៈ ចាបង!!
ខៈ ម៉ែខ្ញុំគាត់អត់ខ្មែរទែ!! គាត់លិវ។
កៈ បងឯងណាអាលក្រក់ខ្ញុំឃើញឡើងស្អាត។
ខៈ ហាហា!!
កៈ ចាបង!! អញ្ចឹងបងអត់ចាថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេណោះ???
ខៈ ចា!!
កៈ អញ្ចឹងតើបងមានចាំកន្លែងពួកគាត់កើយទេបង???ខេត្តណា ភូមិណា ស្រុកណអី???
ខៈ ឪពុកខ្ញុំគាត់និយាយថា។ ពីដើមគាត់អ្នកឈើទាលនឹហបាដោយ។
កៈ ចាបង!!
ខៈ ហើយម៉ែខ្ញុំ។ ស្រុកកំណើតគាត់ពីមុនជាអ្នកកំពុងចាមហូ!!!
កៈ អូឆ្ងាយ!!! ចុះតើពួកគាត់ជួបគ្នាដុយរបៀបណាដែលបង???
ខៈ ចួបគ្នា! ប៉ុលពតជាអ្នករៀបបំអោយ។
កៈ អូ!!! អញ្ចឹងពួកគាត់ប៉ុលពតជាអ្នកតរៀបចំអោយ???
ខៈ ចា!! សម័យប៉ុលពត។ គាត់ជាអ្នករៀបចំទុកដាក់អោយ។
កៈ ចាបង!!
ខៈ បើសិនជាតាមម៉ែខ្ញុំគាត់ថាគាត់មិនយកទេ!! បើថាតាមដែលមិនត្រឹមត្រូវគាត់ថាកាត់មិនយកទេឪនាងឯងហូ!! មុខមាត់ខ្មៅកខ្លាកចឹងហូ!!
កៈ ចាបង!!
ខៈ ចា!! សម័យនឹងម៉ែរបស់ខ្ញុំគាត់ស្អាតណាស់។ អញ្ចឹងបងឯងស្អាតចឹង!! បងកាត់រកម៉ាក់បងឯង???
ខៈ ខ្ញុំកាត់រកបងខ្ញុំ!! បងខ្ញុំគាត់ស្អាត៕
កៈ កាត់រកបងវិញ???
ខៈ ចា!! ខ្ញុំកាត់រកបងខ្ញុំ។ បងខ្ញុំគាត់ស្អាត៕ បងខ្ញុំគាត់ខ្ពស់! មុខគាត់មូល។ ញ្ញមមុខអាក្រក់ជាងគេហើយ។ ព្រោះខ្ញុំទាបកាត់រកឪពុក។
កៈ ចាបង!!
ខៈ បងខ្ញុំខ្ពស់ដូចះអាអូនចឹងហាស់។ រាងខ្ពស់ចឹហឯង។
កៈ ចាបង!! ហើយខ្ញុំវិញរាងតឿហើយក៏អាក្រក់ជាងគេដែល៕
ខៈ ហាហា!!!
កៈ ចា!! អញ្ចឹងតើបងមានចាំអីខ្លះទេពីជីដូនជីតារបស់បងទេ??? ដូចពួកគាត់មានធ្វើអីមួយដែលអោយបងចាំពីពួកគាត់ទេ???
ខៈ អត់ដែលឮពួកគាត់និយាយអោទេ!! គ្រាន់តែម៉ែឪជីដូនជីតាអីពួកគាត់និយាយថា!! គាត់មានស្រែមានចំការអីទុកអោយកូនចៅអញ្ចឹងហាស់៕
កៈ ចាបង!!
ខៈ ចា!! រឿងតកូនតចៅ។
កៈ ចាបង!!!
ខៈ តែបើនិយាយពីរឿងប្រវត្តរបស់គាត់ខ្ញុំអត់ដឹងទេ៕ គាត់អត់ដែលបាននិយាយប្រាប់អីដល់យើង។
កៈ ចាបង!!! សូម្បីតែកន្លែងកើតរបស់គាត់អីក៏បងអត់ដឹងដែលណ៍???

ខះ ចា!! អត់ដឹង៕
កះ ចាបង!! ចុះកាលដែលពួកគាត់ស្លាប់បងកើតទានដែលអត់???
ខះ អូ!!! កាលខ្ញុំកើតពួកស្លាប់អស់ហើយ៕
កះ ចាបង! ពួកគាត់ស្លាប់នៅជំនាន់ប៉ុលពតហីបង???
ខះ ចា!! ប៉ុលពតនឹងឯង!!!
កះ ប៉ុលពតនេះ។ អញ្ចឹងសួរតទៀត។( កន្លែងនឹងអ្នកជិតខាងគាត់មកសួរគាត់)។
អញ្ចឹងតើបងមានដឹងអីផ្សេងទៀតអត់ពីក្រុមគ្រួសាររបស់បងហាស់។
ដូចជានរណាម្នាក់នៅក្នុងគ្រួសាររបស់បងហាស់។តើបងមានដឹងអីពីពួកគាត់ខ្លះទេ???
ខះ ខ្ញុំដឹងតែថា។ ខ្ញុំពេលដែលខ្ញុំធំដឹងក្តីឡើងខ្ញុំនៅជាមួយអ៊ុំ។
កះ ចាបង!!!
ខះ អ៊ុំខ្ញុំនឹង! គាត់ជីដូនមួយនឹងឪពុកខ្ញុំនឹងហាស់។
កះ ចាបង!!
ខះ អញ្ចឹងគាត់អត់មានកូនទេ!!! គាត់សូមខ្ញុំយកទៅចិញ្ចឹម។
តាំងពីខ្ញុំនៅតូចគាត់យកខ្ញុំតៅចិញ្ចឹម។
កះ ចាបង!!
ខះ យកខ្ញុំទៅចិញ្ចឹមទៅ។
ហើយបងខ្ញុំគាត់ទៅនៅជាមួឪពុកខ្ញុំគាត់នៅជាមួយឪពុកខ្ញុំម្ខាងនឹងហាស់អស់ពីម្តាយខ្ញុំអស់ពីម្តាយខ្ញុំទៅ។ ម្តាយខ្ញុំគាត់បាត់ទៅហើយនឹង។ គាត់នៅម្ខាងម្នាក់។
កះ ចាបង!!
ខះ គាត់នៅខាងនេះអូ! ខ្ញុំនៅម្ខាងម្នាក់ចឹង។
កះ ចាបង!!
ខះ ដល់ពេលឪពុលរបស់ខ្ញុំគាត់ទៅមានប្រពន្ធប្រហែលជាមួយឆ្នាំ។
ស្លាប់ទៅគាត់មានប្រពន្ធមួយទៀត។ បានប្រពន្ធអ្នកជ្រួយស្តៅ។
គាត់ឈ្មោះយាយកង។
កះ ចាបង!!
ខះ ពេកដែលគាត់បានប្រពន្ធមួយទៀតគាត់អត់មានកូនមានអីទេ។
ទេគាត់មកនៅជបន្ទុកជាមួយ បងប្អូនខ្ញុំទាំងអស់នឹងហា។
កះ ចាបង!!
ខះ កាលដែលខ្ញុំដឹង!! កាលនឹងខ្ញុំនៅរៀនដែល។
ហើយបងខ្ញុំ!ក៏នៅរៀនដែលតាមដែលខ្ញុំដឹងហាស់។
កះ ចាបង!!
ខះ ហើយខ្ញុំក៏នៅរៀន។
កះ ចាបង!!
ខះ គ្រាន់ទេគេមានអាយុបងបងខ្ញុំមួយឆ្នាំ។
កះចាបង!!!
ខះ ចា!! ហើយទៅរៀនទៅ!! ហើយប្អូនរបស់ខ្ញុំណៅរៀនដែល។
កះ ចាបង!!
ខះ ដល់ពេលយើងធំរៀងខ្លួនទៅ!! យលងចេះតែរស់រៀងខ្លួនទៅណាស់អ្នកគ្រូ។
កះ ចាបង!!
ខះ គេទៅធ្វើការគេទៅ!! ហើយយើងទៅធ្វើការខ្លួនយើងទៅណាស់។
ហើយរហូតដល់យើងមានគ្រួសារ។
កះចាបង!!
ខះ ហយគ្រួសារខ្ញុំជាអ្នកធ្វើស្រែចំការធម្មតាទាំងអស់!!
វាហាត់នឿយនឹងជីវិតខ្លួនឯងហាអ្នកគ្រូ។
កះ ចាបង!!

ខ៖ ប៉ុន្តែខ្ញុំហត់នឿយណាស់ពេលដឹងក្តីឡើង!!! គោ ស្រែចំការ ហត់នឿយ។
ប៉ះស្វាយ! ប៉ះល្អត។ ដឹងគាផដឹងក្តីឡើងនៅលើចុងល្អតបាត់ហើយ។
ក៖ ចាបង!! អញ្ជឹងបងចេះប៉ះល្អត! តាងតេពីនៅក្មេងមក?
ខ៖ ចា!! ចំការខ្ញុំមានល្អតមានស្វាយមានក្រូច។ចា!!
យើងហត់នឿយនឹងជីវិតរបស់យើង។
ក៖ ចាបង!!
ខ៖ គោផង!! គោបី។ យើងវាហត់នឿយ។ អញ្ជឹងការសិក្សាយើងវាមានតិចហាស់៕
យើងវារវល់នឹងតែអារបស់ទព្យនឹងឯង!! វារវល់ប៉ះហាស់។
ក៖ ចាបង!!
ខ៖ កាលខ្ញុំប៉ុនលីសាកូនខ្ញុំតូចប៉ុននឹង។ កាលនឹហខ្ញុំនៅតេចុងស្វាយទេ។
យើងអ្នកប៉ះទៅ!! ហើយម៉ែគាត់ជាអនកជញ្ជូន។ ដាក់អាទេសសេះហាស់!
ប៉ះទៅរុញទៅ។ ទួលផងអីផងទៅ។ ហើយខ្ញុំអ្នកប៉ះ!!
ប៉ះទៅរហូតដល់យប់បានមកផ្ទះ។ ទំរាំតែអស់មារដូវខែស្វាយនឹងខ្ញុំហត់ណាស់។
ក៖ចាបង!!
ខ៖ ខែក្រូចប៉ះក្រូច! ខែស្វាយប៉ះស្វាយ!
ប៉ុន្តែការរៀនសូត្យការសិក្សារបស់យើងវាបានតិចតួចហាស់។
ក៖ ចបង!!
ខ៖ ព្រោះអីយើងរវល់តែអារឿងទព្យរបស់ហូ!!
ក៖ ចាបង!!
ខ៖ ហត់នឿយ! គោស្មៅគោ!! គោបី។
រហូតដល់ពេលដែលយើងមានគ្រួសារគឺជីវិតរបស់យើងវាហត់នឿយរហូត។
ក៖ ចានឹងហើយបង!! អញ្ជឹងបានន័យថាបងប្អូនតបស់បងទាំងអស់!
តើពួកគាត់ងត់នឿយដូចបងដែលឬអត់?
ខ៖ ចា!
ហត់នឿយដូចគ្នាតែបងរបស់ខ្ញុំគាត់វារៀងធូស្រាលជាងគេ៕គាត់មិនសូវហត់នឿយទេ។ គេថាមនុស្សគេថែខ្លួនគេហាស់!! គេឆ្លាតហាស់។
ក៖ ចាបង!!
ខ៖ ពួកគាត់មិនសូវហត់នឿយទេ!! ហត់នឿយជាងគេតែខ្ញុំទេ។
ក៖ ចុះប្អូនរបស់បគាត់ក៏មិនសូវហត់ដែលមែនអត់?
ខ៖ ចា!! មិនសូវហត់ទេ! នៅរៀន។រៀនរហូត។
ពេលប់រៀនបានមួយឆ្នាំមានប្រពន្ធ។
ក៖ ចាបង!! តើពួកគាត់រៀនចប់ថ្នាក់តាំងអស់តើហីបង?
ខ៖ ប្អូនខ្ញុំ! រៀនចប់ទី១២!! រៀនបច់ហើយបង់លុយអោយគេអស់២៥,០០០ដុល្លា!
ថាបំរុងចូលធ្វើពេទ្យចឹងហាស់។
ក៖ ចាបង។
ធ្វើការអោយគេនៅពេទ្យធំយើងនេក។ ដល់ពេលបង់លុយអោយគេទៅ។
ដល់ពេលមានបញ្ហាស្អីគេទេកាលនឹង។ ដូចជាយើងទៅខុសថ្ងៃណាត់។
ក៖ ចាបង!!
ខ៖ អ្នកផ្សេងគេដាក់គេអោយបីពាន់។
ក៖ចាបង!!
ខ៖ ដល់ពេលគេយកគេយកអ្នកផ្សេង។ ខុសគ្នាតែតិចសោះនឹង។
ក៖ ចាបង!!
ខ៖ ខុសគ្នាប្រហែលមួយម៉ោងថ្ងៃនឹង។
ក៖ ចាបង!!
ខ៖ អញ្ជឹងបានថា!! គេដាក់បីពាន់គេយកអាអ្នកបីពាន់នឹងទៅ។
ហើយយើងក៏អត់បានធ្វើដល់សព្វថ្ងៃនឹងទៅ។
ក៖ ចាបង!!

ខ៖ ចោលលុយទទេអត់បានអីទាំងអស់???
ក៖ ចាបង!! អញ្ចឹងកាលសម័យនឹង! គេពុករលួយហើយ? និយាយចឹងចុះ! គេយកលុយហើយហីបង?
ខ៖ ចាចា!! កាលនឹងពុករលួយ!! គេយកលុយហើយ។
ក៖ ឆ្នាំប៉ុន្មាណហើយកាលនឹងបង?
ខ៖ យូរហើយ!!! កាលណឹងដូចជាបច្រើនឆ្នាំហើយកាលនឹង។
ក៖ ឆ្នាំពីពាន់ហើយនៅបងកាលនឹង?
ខ៖ នឹងហើយប្រហែលជឆ្នាំពីពាន់ហើយ។
ក៖ ចា!! កាលនឹងកំពុងហើយ!!!
ខ៖ចា!! ប្រហែលជាឆ្នាំពីពាន់នឹងឯងកាលនឹង។
ក៖ អញ្ចឹងតាមអ្វីដែលបងបានប្រាប់មកខ្ញុំថា។
បងមានបងប្អូននៅក្រៅប្រទេស!! ប៉ុន្តែពួកគាត់ត្រូវជាអ៊ុំពូរបស់បងតើហី?
ខ៖ ចា!! ត្រូវជាអ៊ុំរបស់នង្កើត។ ត្រូវជាប្អូនរបស់ឪពុករបស់ខ្ញុំ។
ក៖ ចាបង!!
ខ៖ ចា!! ហើយបង! បងគាត់មានកូនបី។
ក៖ ចាបង!!
ខ៖ ចា! ស្រីពីរប្រុសមួយ។ ឈ្មោះចំណាប់ចំណាន។
ក៖ ចាបង!!
ខ៖ ហើយកូនគាត់ប្រុសពៅនឹង!! ខ្ញុំមិនដឹហថាឈ្មោះអីទេ។ ខ្ញុំភ្លេចបាត់ហើយ។
ក៖ ចាបង!! អញ្ចឹងពួកគាត់រស់នៅរដ្ឋជាមួយគ្នា? រដ្ឋកានីហ្វូញ៉ា?
ខ៖ ចា!! ពួកគាត់រស់នៅរដ្ឋជាមួយគ្នា។ ពួកគាត់មានប្តីមានកូនអស់ហើយចា!!
ហើយអាប្រុសពៅនឹងគេមានកូនមានប្រពន្ធអីអស់ហើយ។
ក៖ តើពួកគាត់បានប្រពន្ធជនជាតិឬក៏ខ្មែរ?
ខ៖ បែបប្រពន្ធជនជាតិទាំងអស់ហើយ!!!
ក៖ ជនជាតិទាំងអសណ៌បង?
ខ៖ ចា!! ជនជាតិហើយ។
ក៖ នឹងហើយបង!!ចា!
នឹងហើយតើបងអាចប្រាប់ខ្ញុំពីខ្សែជីវិតរបស់បងពេលធំឡើងយ៉ាងដូចម៉េចដែល? ដូចជាពីជីវិតពីជីវិតរបស់យើងពីក្មេងរហូតដល់ធំឡើងជួបអីគេខ្លះក្នុងជីវិត???
ខ៖ ខ្ញុំនឹងហះ?
ក៖ ចាបង!!
ខ៖ ហី!!! តាំងពីដឹងក្តីរហូតដល់ជីវិតដែលយើងមានគ្រួសារនេះហះអ្នកគ្រូ!!
ក៖ ចាបង!!
ខ៖ គឺវាជួបនឹងអារឿងលំបាកជាំច្រើនវាហត់នឿយហាស់!!
វាហត់នឿយទាំងផ្លូវកាយទាំងផ្លូវចិត្ត។ និយាយទៅវាហត់នឿយទាំងអស់។
កំលាំងហត់ច្រើន!!!
ក៖ ចាបង!!
ខ៖ វាគិតច្រើន!! មិនថាមានប្តីហើយ!! ហី! យកប្តីមិនអោយពិបាកចិត្ត។
តាមពិតមានមាននឹងហាស់! វាពិបាកលើសដើម។
ក៖ ចាបង!!
ខ៖ យើងនៅជាមួយឪពុលម្តាយ!!
ពេលអត់មានឈ្លានសុំអីយើងមិនសូបគិតទេណាស់។
ក៖ ចាបង!!
ខ៖ ដល់ពេលដែលយើងមានគ្រួសារទៅ។ យើងគិតពីកូន!! គិតពីប្តី!!
ចាគិតគ្រប់មុខហាស់!!! ឈើជា។ ហោកឯណាបាយទឹកយប់ប្រលប់។
ហើយយើងខំទាំងឈើទាំងជាដើមប្បីកូន។
ដើមប្បីចិញ្ចឹមកូននឹហឯង។

ក៖ ចាបង!!
ខ៖ បើយើងនៅជាមួយម៉ែឪ!! អត់មិចគឺថម៉ែជាអ្នកជួយហាស់។ ផ្គត់ផ្គង់!!
គាត់មិនអោយយើងអត់សីទេចា។
ក៖ ចាបង!!
ខ៖ ដល់ពេលដែលយើងមានប្ដីទៅ!! គឺត្រូវបែកហើយ!!
គ្មានម៉ែឪណាមកចាំជួយយើងទៀតទេ។ គឺខំដោយកំលាំង។
ខំដោយកំឡាំងហាស់ចា!
ក៖ ចាបង!!
ខ៖ ចា!! តាំងពីរៀបការមកគឺហត់នឿយរហូត។ គ្រាន់តែការងារងត់នឿយមែន!
តែវាជារបស់ខ្លួឯង។
ក៖ ចាបង!!
ខ៖ ខ្ញុំអត់មានហត់នឿយបើថាទៅធ្វើការអោយគេធ្វើខ្ញុំគេអីគឺអត់មានទេ។
ក៖ ចាបង!!
ខ៖ គឺហត់នឿយនឹងទព្យរបស់ស្រែចំការរបស់ខ្លួនឯង។
ក៖ ចាបង!!
ខ៖ បើសិនជាយើងមិនធ្វើ!! វាអត់មានអ្នកណាធ្វើ!! របស់យើងមាន។ ចា!
វាអញ្ចឹង។
ក៖ ចាបង!! ដូចថានៅពីក្មេងយើងលំបាកមែនតែលំបាក!
នៅក្នុងគ្រុមគ្រួសារឪពុកម្ដាយពួលគាត់ជាអ្នកមើលថែយើង។
ខ៖ ចា!! នៅក្នុងការគ្រប់គ្រងអត់មានហត់អីទេចា!!
ហើយអត់មានភ័យខ្លាចថាអត់អីទេចា។
ហើយបើយើងម៉េចៗម៉ែឪគាត់ជាអ្នកផ្គត់ផ្គង់។
ក៖ ចាបង!!
ខ៖ ហើយដំណាំដំណោចស្រែចំការរបស់យើងមានវាមិនភ័យថា!! ហឺ!
ចាំដើររកសីជំពាក់បំណុលគេទេ។ តែដល់ពេលដែលយើងមកមានគ្រួសារ។
យើងចេះជំពាក់បំណុលគេ។
ក៖ ចាបង!!
ខ៖ ចេះជំពាក់គេ!! ចា! ចេះជំពាក់គេ! ពិបាកអារឿងកូនផ្សេង!
ហើយណាមួយរឿងគ្រួសារហើយប្ដីនោះផ្សេងទៅ។
មិនដឹងថាធ្វើការរកសុីស្អីអោុមានអាផលនឹងទប់ហាស់។
ក៖ ចាបង!!
ខ៖ រកអាកំរៃនឹងមកទប់ទល់នៅក្នុងគ្រួសារ។
ហើយនឹងឃើញថាបើនៅក្នុងគ្រួសារ!!
បើសិនជាមានប្ដីឬប្រពន្ធត្រូវឈឺអីយ៉ាប់ហាស់!!!
ក៖ ចាបង!!!
ខ៖ ចា!! បើសិនជាត្រូវអស់អ្នកជំហារនឹងត្រូវយោះហើយ!!។
ក៖ ចាបង!!
ខ៖ ប្ដីខ្ញុំសព្វថ្ងៃនឹងក៏អញ្ញញចឹងដែល។ ថាបើសិនជាខ្ញុំឈឺ! ឬក៏ប្ដីខ្ញុំវិញត្រូវឈឺ!
នឹងត្រូវយ៉ាប់ហើយណាស់។ ចា!
ក៖ ចាបង!!
ខ៖ វាខ្វះអាកំឡាំងរកនឹងហាស់។សូម្បីតែសព្វថ្ងៃនេះរកក៏ទប់ទល់អត់ឈ្នេះដែល។
ក៖ ចាបង!!
ខ៖ បើសិនថារកបានដប់ចាយដល់មួយម្ភៃ!! ដឹងហាអ្នកគ្រូ!
ដឹងខ្លួឯងច្បាស់ណាំស់នៅក្នុងគ្រួសារ។ចា!
ក៖ ចាបង!!
ខ៖ យើងបើអត់ល្អមទេ!! តែកូនវិញព្រឹកឡើងវាត្រូវតែចាយ។
ចាក់សាំងគេសុីចុក។ បើមិនអញ្ចឹងគេធ្វើមិចមានកំឡាំងទៅធ្វើការ?

កៈ ចា!ត្រូវហើយបង។
ខៈ ហើយយើងនឹងទៅហួងហែងគេម៉េច??! បើគេខំរកខំធ្វើការ!!!
កៈ ចាត្រូវហើយបង!!
ហើយបើសិនជាយើងញ៉ាំអត់ដឹតដល់ក៏យើងទៅចូលការអត់មានកំឡាំងធ្វើអោយ
គេដែល!!
ខៈ ចា! បើសិនជាយើងហូបអត់បានជិតដល់ក៏វាយ៉ាប់ដែល!!! យើងថាទៅ!
អោយយើងនឹងវាថាអោយគេយ៉ាងម៉េច?
កើ ចាបង!!
ខៈ យើងថាទៅកែថា!! បើយើងខំរកមិនអញ្ចឹងខំរកមកធ្វើអី???
អញ្ចឹងបើសិនជាំយើងនិយាយទៅនាំតែឈ្លោះគ្នា។
កៈ ចាបង!!
ខៈ ហើយប្ដីខ្ញុំគាត់ជាអ្នករក!
អ្នកធ្វើការចឹងមែនតែគាត់មិនបានអោយលុយមកខ្ញុំទាំងអស់អីនោះទេ។
នេះខ្ញុំប្រាប់ត្រង់។ គេមិនបានអោយមកយើងទាំងអស់នោះទេ!!
បើថាបានមកដដប់ចឹង!! គេអោយមកយើងបួនឬក៏ប្រាំ។
កៈ ចាបង!!
ខៈ នេះខ្ញុំនិយាយប្រាប់ត្រង់ហាស់!!!
កៈចាបង!!
ខៈ ខ្ញុំនិយាយនេះនិយាយពាក្យពិតអត់មានកុហក់ស្អីទេ!!!
កៈ ចាបង!!
ខៈ បើគេបានមកដប់។ គេអោយមកយើងតែឬក៏ប្រាំអីទេ!!
ព្រោះអីពេលខ្លះកូនជាងវាត្រូវការខ្ចីលុយ។ មាខ្ចី៤,០០០០! ១,០០០០រៀល
២,០០០០រៀល កូនខ្ញុំឈើត្រូវការតិញអង្ករមួយការ៉ុង។
ហើយយើងមានលុយឯណាទៅគេ ។ ហើយមកយើងលុយពីយើងនេះ!!
ហើយមានលុយណាទៅអោយគគេ?
កៈ ចាបង!!
ខៈ
ហើយចឹងពេលមាននៅក្នុងខោបៅពេលដែលគ្នាត្រូវការខ្ចីលុយក៏កយើងរកលុយ
បរិលអោយគ្នាទៅ។
កៈ ចាបង!!
ខៈ ចា!! បើសិនថាយប់ប្រឡប់អី!! ម៉ូតូខូចអី។បើគេចង់សុ៊ីចាយអី!
គេមានលុយខ្លួនគេ។
កៈ ចាបង!!
ខៈ វាអត់ពិបាកត្រង់ថា!!
សុំ១,០០០ឬក៏៥,០០០អីជក់បារីទាពីប្រពន្ធគឺអត់មានទេ។
វាអត់ពិបាកត្រង់នឹងហាខ្ញុំ។
កៈ ចាបង!!
ខៈ ចា!! ហើយក៏ទាគេដែល!! បើធ្វើការ! អត់មានសល់។
អោយយកពីណាមកអោយ!!! ហើយយើងទៅនិយាយម៉េចនាំតែឈ្លោះគ្នា។
កៈ ចាបង!!
ខៈ ដលពេលអញ្ចឹងទៅ! ខ្ញុំខិល។ ខ្ញុំអត់សួរនាំអីទេ។ បើគេអោយយើងអោយ។
បើគេមិនអោយយើងអត់នឹងឯង។
កៈ ចាបង!!!
ខៈ ហើយគេក៏ជួយយើងបំការនៅក្នុងគ្រួសារហើយ។
បើគាត់មិនបាជួយចេញអានុះក៏គាត់ជួយចេញអាផ្សេងអីដែល។
គាត់ជួយផ្ទុំយើងដែលហាស់។
កៈចាបង!!

ខ៖ ហើយបើយើងជំពាក់អង្គការអីអញ្ចឹងគឺជំពាក់ជុំគ្នាមិនមែនតែមួយទេ។
ក៖ ចាបង!!
ខ៖ ប្តីគឺប្រពន្ធហើយ។ ជួយសងដោះគ្នាទៅ។ គាត់ជួយយើងគ្រប់មុខដែល។
ក៖ ចាបង!!
ខ៖ប៉ុន្តែជីវិតវាមានតែលការហត់នឿយវាអត់មានអាការស្រណុកមិច!!
វាអត់សប្បាយដូចគេហាស់។ វានឿយមួយជីវិតមកហើយ! វាហត់នឿយណស់។
ក៖ ហត់នឿយរហូត!!!
ខ៖ ចា!! នេះតាំងពីមានប្តីមកថារៀងគ្រាន់វិញតិចហើយ។
បើថាកាលនៅពីក្រមុំវិញ។ ហត់នឿយជាងនេះទៅទៀតខ្ញុំប្រាប់!!!
ក៖ ហឹ!!!
ខ៖ ហត់នឿយណាស់!!!
ក៖ អញ្ចឹងបានថា!
ពួកខ្ញុំធ្វើមួយនេះដើម្បីអោយកូនចៅជំនាន់ក្រោយរបស់បងពួកគាត់បានស្តាប់
ថា! ឪពុកម្តាយហើយនឹងយាយតា!
ពួកគាត់បានជួបនៅការលំបាកអ្វីខ្លះនៅក្នុងជីវិតរបស់ពួកគាត់ចឹងហាស់បង។
ខ៖ ចា!!
ក៖ ចាបង!! អញ្ចឹងពេលខ្លះពួកយលងបានកើតមកស្រួល!
អត់បានដឹងថាតើជីវិតនឹងវាពិបាកយ៉ាងម៉េចខ្លះអីអត់ដឹងទេ។
ខ៖ ចា!! អត់ដឹងទេ។
បើជីដូនជីតាខ្ញុំមកខ្ញុំបានឪពួកគាត់និយាយពួកគាត់ធ្វើតែស្រែចំការ។
ក៖ ចាបង!!!
ខ៖ ធ្វើតែស្រែចំការ!! ចុះដីរបស់ពួកគាត់កាលនឹងចំៗហាស់។
សុទ្ធតែបួនដប់ហិគតា។ ធ្វើតែស្រែទេ។ តែធ្វផ្ទះធំៗហាណាស់!!!
ក៖ ចាបង!!!
ខ៖ ចាផ្ទះធំ!! ផ្ទះរបស់ខ្ញុំនៅលើ!សសរម្កៅដើម។
ក៖ វាយ!!! ចំមែនទេនបង!!
ខ៖ ចាផ្ទះធំ!! ធំដូចប្រហារចឹងហាស់អ្នកគ្រូ។ ផ្ទះពីដើមហាស។!
ធ្វើតែស្រែលក់តែស្រូវនឹងឯង។ ផ្ទះភ្លោះពីដើមហាស់!! ពិដើមហាស់។
ធ្វើតែស្រលក់តែស្រូវទេពីដើម។
ក៖ ចាបង!!
ខ៖ ហើយលក់ទៅទិញឈើទិញក្តារសុទ្ធតែល្អៗហាស់។
ក៖ ចាបង!!
ខ៖ ចា!! ដល់ពេលធ្វើទៅ។ អាពតវារើរអស់មួយ!! ឥឡូវនេះនៅសល់តែមួយទេ៕
ក៖ អញ្ចឹងផ្ទះរបស់បង។ម្តាយរបស់បង! អ៊ុំយាយដែលគាត់នៅសព្វថ្ងៃនឹង!!
ដូចផ្ទះបុរាណចឹងដែលនបង?
ខ៖ ចា!! ផ្ទះបុរាណ!!! តែវារើរជញ្ជាំងអស់។ វារើរអាផ្ទះមួយអ់នៅខាងកើតផ្លូវ!!
ឪពុកខ្ញុំគាត់មានផ្ទះបុរាណមួយ។ ទាំងអស់មានពីរហាស់!!!
ក៖ ចាបង!!!
ខ៖ នៅខាងនេះមួយ! ខាងនោះមួយ។ ដលពេលអញ្ចឹងទៅ។ អាពតវារើរអស់ទៅ។
វាមករើរមួយទៀត។ មករើរជញ្ជាំង។ រើរជញ្ជាំងទាន់យើងចូលមកដល់ហេក!!!
ក៖ ចាបង!!!
ខ៖ នៅពេលដែលយួនគេចូលមករមដោះហេក!!! គេហៅថាស្អី?
ប្រាំពីមករាម៉េចគេទេកាលនឹង!!!
ក៖ ចានឹងហើយបង!!!
ខ៖ មកដល់អញ្ចឹងទៅ!!! វារត់របាត់របាយទៅ! វារើរបានតែជញ្ជាំងផ្ទះពីទេ។
កុំអីអស់រលីងបាត់។
ក៖ ចាបង!!!

ខៈ ដល់នៅសព្វថ្ងៃ!!! រួចម៉ែរបស់ខ្ញុំគាត់ដុំផាងដូងយើងពីដើមហាស់!។
កៈ ចាបង!!!
ខៈ ហើយយកវាមកធ្វើផាំជញ្ជាំង! ដល់សព្វថ្ងៃបនេះបក់សង្ស័យអស់ហើយ។
កៈ ចាបង!!
ខៈ ប៉ុន្តែសសរអី!ហើយនឹងក្បឿងអីនៅទាំងអស់ចឹង!!
ប៉ុន្តែវាអន់តាគ្រង់ជញ្ជាំងផ្ទះយើងវារៀងគ្រុតគ្រោមហាស់។
កៈ ចាបង!!
ខៈ បើសិនជាខ្ញុំមានលុយខ្ញុំកែកុនវាហើយ៕
ល់ពេលយើងអត់លុយចឹងទៅវាធ្វើអត់កើត៕
កៈ អញ្ចឹងផ្ទះនឹងគេដាក់ធកវើជាផ្ទះបុរាណអីទេ???
អោយភ្ញៀងទេសចរណ៍ចូលទៅមើល៕
ខៈ ចុះនៅភូមិខ្ញុំនឹងពួកបារាំងអី។ ពួកវានាំគ្នាទៅថតដែលតើ!!!
ដូចជានៅភូមិវត្តគរអីដែលនឹងហាស់។
កៈ ចាបង!! មានគេសុំចូលទៅថតរូបអីដែលតើហី?
ខៈ ចាមាន!!! ចុះបើនៅនឹងមាត់ថ្នល់នឹងស្រាប់ហើយ។
កៈ អូ!!! ចា។
ខៈ ហើយបើផ្លូវវិញគេចាក់បេតុង។ គេឈរថតនៅមាត់ផ្លូវ។
កៈ ចាបង!! ចាំថ្ងៃណារកទៅលេង។
ខៈ ចា!!
កៈ សរសរម្កៃធំហាណាបង!!!
ខៈ ចាធំ!!! ផ្ទះវាមានបួនខ្នងហាស់!!!
កៈ អូវ៉ាយ!!!
ខៈ ប៉ុន្តែជីវិតម៉ែឪមកគឺធ្វើស្រែចំការ!! អត់មានថា!!
ទៅពឹងកំលាំងអ្នកណាញើសឈមអ្នកដទៃអីគឺអទ់មានទេ!
មាសទាំងដុំអីគឺអត់មានទេ។ គឺខំប្រឹងរកដោយខ្លួនឯងសុទ្ធ។
ប៉ុន្តែសូម្បីតែមកដល់សព្វថ្ងៃនេះក៏គាត់នៅតែនឿយហតដែល!!!
កៈ យាយហ្វូ?
ខៈ ចា!! នៅតែធ្វើស្រែធ្វើចំការដូចតែគ្នា។
កៈ អញ្ចឹងតើម៉ាក់របស់បងឥឡូវតើគត់មានអាយុប៉ុន្មាណហើយ?
ខៈ ម៉ាក់ខ្ញុំនឹងត្រូវជាអ៊ុំរបស់ខ្ញុំទេណាស់។
កៈ ចាបង!!!
ខៈ
អ៊ុំនឹងហើយដែលគាត់ចិញ្ចឹមខ្ញុំមកតាំងពីខ្ញុំនីជាកូនងារមកម្ល៉ះមកនឹងហាស់។
កៈ ចាបង!!
ខៈ ឥឡូវនឹងគាត់ ៧០ ជាងហើយ។ គាត់វង្វេងម្តងៗហើយ។
កៈ អូចា!! ត្រូវហើយដោយសារតែម្តាយរបស់បងគាត់ស្លាប់តាំងពីគាត់អាយុ ៤៥
មកមែកាលគានទេ?
ខៈ ចា!! ចេក! អ៊ុំរបស់ខ្ញុំនឹងគាត់អត់មានកូន!។
ហើយគាត់យកខ្ញុំមកចិញ្ចឹមនឹងតាំងពីខ្ញុំមានអាយុប្រាំមួយប្រាំពិលខែ។
កៈ ចាបង!!
ខៈ កាលដែលគាត់យកខ្ញុំមកចិញ្ចឹមនឹងហាស់!!!
កៈជាបង!!
ខៈ ម៉ែរបស់ខ្ញុំគាត់ស្អប់ខ្ញុំណាស់។ ដោយសាតែខ្ញុំកាចហើយខ្មៅ។
កៈចាបង!!
ខៈ ខ្ញុំឮសូរគេឬគាត់និយាយទេណាស់។
កៈ ចាបង!!

ខៈ ចល់ពេលទំលាក់ខ្ទ។ចោលទៅ! វារុះ!!
ក៏ចំស្រមោចភ្លើងកផចំស្រមោចភ្លើងចំទៅវាខំ។ដល់ពេលវាខាំទៅ។
យំហើយក៏ដើរមក។
កៈ ចាបង!!
ខៈ ដល់ពេលឮយើងយំពេកក៏គាត់ដើរមក។ ឮយើងយំដល់ត្រើយខាងនេះហាស់។
កៈ ចាបង!!
ខៈ ហើយម៉េចមមិនមើលកូន!! ទុកអោយកូនយំអីក៏សំបើមម្ល៉ះ។
កៈ ចាបង!!
ខៈ ដល់ពេលគាត់ទៅមើលក៏ឃើញខ្ញុំនឹងនៅជិតផេះ( នៅជិតចង្ក្រាង) នឹងហាស់។
ស្រមោចភ្លើងវាខាំវារមាស់វាហូ!!!
កៈ ជាបង!!
ខៈ ដល់ពេលឈើចឹងទៅគាត់ក៏រើស!! រើសយកមកលាបថ្នាំអោយ។
យកថ្នាំមកលាបអោយចឹងទៅគាត់ក៏ថា។
បើហែងមិនចិញ្ចឹមវាអោយមកអញ់មកអញ់យកមើល!! អញ់អត់មានកូន។
បើវាខ្មៅចឹងអោយមកអញ់មក! អញ់ចិញ្ចឹម។ បើវាខ្មៅចឹងហូ!!៕
អានេះខ្ញុំឮសួរតែគាត់និយាយទេណា។
កៈ ចាប៉ង!!
ខៈ ហើយម៉ែខ្ញុំគាត់ក៏ថា!! អើយកទៅអោយបាត់ៗទៅ។
ចាំដល់ពេលវាំបៅចាំយកមក។ ដល់ពេលបៅរួចទៅក៏ពរទៅដេកវិញទៅ។
ដល់យំទៀតទៅគាត់ពរឆ្លងផ្លូវមកអោយបៅវិញ។
កៈ ចាបង!!
ខៈ ចា!!! នេះហើយជីវិតរបស់ខ្ញុំគឺវាអញ្ជឹង។
កៈ ចាបង!!!
ខៈ ហើតគាត់យកទៅនៅបានប្រាំមួយខែទៅនៅ! វាកតែអាចម៍។ ឈើពោះ!!
ឡើងក្រពោង។ ខឿវហាស់។
កៈ ចាបង!!
ខៈ ដល់ពេលឃើញសរសៃទៅ។ យកទៅជួសតានផងអុជផងទៅ។
អញ្ជឹងបានគេហៅមីក្អៀកជាប់។
កៈ ចាបង!!!
ខៈ ចា!! កាលនឹងវាអញ្ជឹងឯងចា!!
កៈ ចាបង!!
ខៈ ចា!! សព្វថ្ងៃគាត់មានប្តីមួយ!!! បងប្អូនរបស់គាត់មានបីនាក់ហាស់។
កៈ ចាបង!!!
ខៈ ស្លាប់អស់មួយនាក់បាត់ហើយ!! នៅពីនាក់តែអត់មានកូនទេ។
មួយនៅក្រមុំចាស់! តែពួកគាត់សិទ្ធតែជរាអស់ហើយ។ ពួកគាត់មានអាយុ
៧០ឆ្នាំជាងអស់ហើយ។
កៈ ចាបង!!
ខៈ តែនៅតែធ្វើស្រែ! ធ្វើចំការចឹងេងចា។
កៈ តែកូនរបស់ពួកគាត់មានអាយុ៧០ឆ្នាំជាងអស់ហើយ?
ខៈ មិនមែនតែ។ ម៉ែរបស់គាត់!!
កៈ អូ!!!
ខៈ ម៉ែរបស់ខ្ញុំនឹងណាស់។ ពួកគាត់អត់មានកូនទេ។ វៃគាត់សុទ្ធតែចូល
៧០ឆ្នាំជាងអស់ហើយ។ គេហៅថាចូលវៃចាស់ជរា។
កៈ អូ!ចាបង!!
ខៈ ចា!!!
កៈ អញ្ជឹងតើម្តាយរបស់បង!!! ពេលដែលបងរបការតើគាត់នៅទាំន់ដែលតើហី?
ខៈ អត់ទេគាត់ស្លាប់មុនខ្ញុំរៀបការ។

ក៖ អូ!!! អញ្ចឹងមាននៃថា! អ្នកដែលរៀបការអោយបងនឹង។
គឺម្ដាយដែលបានយកបងទៅចិញ្ចឹមនឹងមែន?
ខ៖ ចានឹងហើយ!!!
ម្ដាយដេលយកខ្ញុំទៅចិញ្ចឹមនឹងឯង៕ចាគាត់នឹងហើយជាអ្នកដែលផ្គត់ផ្គង់អោយ
។
ក៖ អូចា!!!
ខ៖ មើលពេលដែលម្ដាយខ្ញុំស្លាប់បាត់ចឹងទៅ!! ពេលនឹង!
គាត់យកយើងទៅចិញ្ចឹមមុនហាស់!!!
ក៖ ចាបង!!!
ខ៖ ពេលដែលខ្ញុំធំឡើងដឹងក្ដី!! គាត់ជាអ្នកដែលទុកដាក់អោយយើងហើយ។
ហើយគាត់គឺមានចែកដីអោយយើងខ្លះដែល!!
ក៖ ចាបង!!
ខ៖ ដីស្រែចំការគឺគាត់ចែកអោយ!! ចា!! ឪពុលម្ដាយ។
ឪពុកខាងណោះក៏ចែកអោយ។ ឪពុកខាងនេះក៏ចែកអោយដែល!!
ពុកគាត់ចែកអោយទាំងអស់! វាបានទាំងសងខាង។
និយាយទៅវាបានពីឬចំនែក។ អញ្ចឹងហាស់!!
ក៖ ចាបង!!
ខ៖ ចុះគាត់ស្រឡាញ់យើងដូចជាកូន។ គាត់បានចិញ្ចឹមយើងតាំងពីកូនងារមក។
ដោយសារតែគាត់អត់មានកូនហាស់។ ចា!!
ក៖ ចាបង!! ចុះខ្ញុំឮសូរបងឯងហៅបងហៅម៉ាក់បងនៅស្អីគេ???
គេហៅអីគេបងកន្លែែដែលគាត់រស់នៅសព្វថ្ងៃនឹង?
ខ៖ គេហៅថាស្ដៅ។
ក៖ ស្ដៅ?
ខ៖ ចា!!
ក៖ ចាបង!! ខ្ញុំស្មានតែគាត់ជាម្ដាយបង្កើតរបស់បហតើ។
ខ៖ នឹង! អត់ទេគាត់ជាម៉ែចុង!!! ត្រូវជាម៉ែទីពីរ។
ក៖ ចាបង!!
ខ៖ តែឥឡូវគាត់ឈ្លោះគ្នាជាមួយឪពុកគាត់ដែលហើយ។
ហើយឪពុករបស់ខ្ញុំនឹងគាត់មកនៅឯឈើទាលនេះជិតដប់ឆ្នាំអីដែលហើយ។
ចាស់ហើយនឹងហាស់!!! អាយុ៧០ ជាងហើយនឹងនៅតែឈ្លោះគ្នា! ខ្ញុំរៀងខឹងដេល។
ក៖ ចាបង!!
ខ៖ ហើយខ្ញុំជាអ្នកទៅយកអោយប្ដីរបស់ខ្ញុំជាអ្នកទៅយក។
ក៖ ចាបង!!
ខ៖ ឈ្លោះគ្នា។ យាយនឹងគាត់បានតា។ គាត់មានកូនចិញ្ចឹមមួយ។
កូនប្រុសហាស់!!!
ក៖ ចាបង!!
ខ៖ យាយថាពីផេកអើយផឹក!!!! រករឿង។ ខុសអីតិចបន្ទោសតែតា!
ហើយវៃដេរអស់ហើយ។ ហើយឈ្លោះគ្នាទៅអត់ដាំបាយ!!
អត់ដាំបាយទុកអោយហូបទេ។ ពេលគាត់ដាំបាយរួចទៅ។
គាត់ដួសបាយអស់ហើយផ្កាប់ឆ្នាំង។
ក៖ ចាបង!!!
ខ៖ ហើយឪពុកខ្ញុំគាត់ទៅចំការគាត់ទៅធ្វើស្មៅហូ!!!
ក៖ ចាបង!!
ខ៖ ទៅជីកដាក់គល់ក្រូច!! ដូចជានៅមុខផ្ទះរបស់អ្នកគ្រូចឹងហាស់!!!
ក៖ ចាបង!!
ខ៖ ដាក់ហើយមើលថៃ!! ដល់ពេលដល់ខែក្រូចផ្លែអោយរយោង!៕
ក៖ ចាបង!!

ខ៖ ដល់ពេលមកពីធ្វើការវិញទៅ!! បាយផ្កាប់ឆ្នាំ។
ដល់ពេលសួរយាយទៅណាបាយ???
ក៖ ចាបង!!
ខ៖  យាយថា! ដួសលៀងសុិផ្កាប់ឆ្នាំងអស់ហើយ។
បើឈ្លានសុិទៅដាំសុិខ្លួនឯងទៅ។
ក៖ ចាបង!!
ខ៖ គ្មានអ្នកណាដាំបំរើទេ។ យាយនឹងគាត់ថាអោយឪពុកខ្ញុំអញ្ចឹងហាស់!!!
ក៖ ចាបង!!ហើយគាតដាំហូបតែខ្លួនគាត់???
ខ៖ ចាគាត់ដាំបាយហូបតែខ្លួនគាត់។ ហើយគាត់ខឹងតារឿងដាច់ខ្សែភ្លើង!!!
ហើយតាគាត់ក៏ថាខឹងរឿងដាច់ខ្សែភ្លើងម៉េច!!
ខ្សែភ្លើងនឹងអាញ់មិនបានធ្វើដាច់ទេ!!! កូនឯងទេដែលជាអ្នកធ្វើដាច់។
កូនរបស់គាត់ដែលគាត់យកមកចិញ្ចឹមនឹងហាស?
ក៖ អូចា!!!
ខ៖ វាមកពីថៃ!
ដល់តែពេលពួកវាសីផឹកពួកម៉ាកពួកជើងនឹងវាដោះអាខ្សែភ្លើងនឹងត!
ចុះវាដាច់ហូ!!!
ក៖ ចាបង!!!
ខ៖ ចា!! ហើយដល់ពេលគាត់ត្រនប់មកពីវត្តវិញហូ!!!
គាត់មិនដឹងថាដដាច់ត្រង់ណា។គាត់ដែលចេះជរើហ៎ះគាត់មនុស្សចាស់ហូ!!!
ក៖ ចាបង!!
ខ៖ ហើយដល់ពេលគាត់មកពីវត្តដើមៗ!! បន្ទោសគាត់ហាស់។ ស្អីតិចអាកាបាក់!
ស្អីតិចបន្ទោសអាកាបាក់។
ក៖ ចាបង!!
ខ៖ ដល់ពេលចឹងទៅគាត់ដេញហាស់!! គាត់ដេញពីរបីដង! គាត់ដេញច្រើនដង។
ក៖ ចាបង!!
ខ៖ ដល់ពេលហើយទៅ!! គាត់ក៏ខលហៅខ្ញុំ! គាត់មិនដែលដាច់ចិត្តទេណា៎។
ដល់ពេលខលហៅទៅ! អានីនអើយមកយកឪទៅផ្ទះអញ្ចឹងហាស់។
ក៖ ចាបង!!
ខ៖ ហើយខ្ញុំសួរមូលហេតុ។ ខ្ញុំប៉ុន្តែខ្ញុំអត់ទៅទេ! ខ្ញុំអោយប្តីខ្ញុំទៅ។
ក៖ ចាបង!!
ខ៖ហើយខ្ញុំក៏ថាពុកឯងគិតអោយច្បាស់។
ខ្ញុំមិនមែនយកពុកឯងមកហោងហែងចង់បានអីទេ។
ក៖ ចាបង!!
ខ៖ បើពុកឯងថាមកថាមកអោយច្បាស់។ កុំថាទៅហើយមកវិញហាស់។
ក៖ ចាបង!!
ខ៖ ខ្ញុំអត់មានអត់មានមកយកពុកឯងដេឡើងដឹកចុះទេ!!!
ក៖ ចាបង!!
ខ ខញ្ញញុំចង់អោយពុកឯងសំរេបចិត្តអោយបានច្បាស់។
បើថាពុកេងទៅរៀបចំខោអាវនៅនឹងវត្តនឹងហាស់។
ក៖ ចាបង!!
ខ៖ ភួយម៉ុងអី! មិនបាច់រៀបចំអីច្រើននោះទេ។ ខោអាវពុកឯងអី!!
រៀបចំទៅតែពីរបីខោភ្លែបានហើយមិនបាច់យកអីមកច្រើនទេ។
ក៖ ចាបង!!
ខ៖ គាត់ដែលឪពុករបស់ខ្ញុំថា!! ខ្ញុំឮសួរឪពុកខ្ញុំគាត់និយាយប្រាប់ខ្ញុំថា (
ប្រពន្ធគាត់ថាអោយគាត់ ) កាលឯងមកឯងអត់មានអីទេ!!
ឪពុកទៅយកលុយទៅរាប់លានដុល្លារ! ហើយ មាសហាស់!
មាសឪពុកខ្ញុំយកទៅឡើងអស់ហើយនឹង!!!

កៈ ចាបង!!
ខៈហើយគាតថាឳពុលខ្ញុំគាំត់អត់មានអីទេ៕
ហើយគាត់ឳពុកខ្ញុំមកវិញអត់មានអីទេមានតែខ្លួន!!!
កៈ ចាបង!!
ខៈ ហើយខ្ញុំអត់មានទាមទាចង់អោយពុកឯងទាមទាអីយកមកទេ។
កៈ ចាបង!!
ខៈ ខ្ញុំថាបើពុកឯងមកបានមក!! មិនបាច់យកអីមកទេ!!
កៈ ចាបង!!
ខៈកូនបីនៅនេះ! វាអាចនឹងចិញ្ចឹមពុករស់ហើយចា!!
កៈ ចាបង!!
ខៈ ចា!! ហើយដល់ពេលអញ្ចញចឹងទៅ។ ខ្ញុំក៏អោយប្ដីខ្ញុំទៅយក!
ប្រហែលជាម៉ោង១១ថ្ងៃ។
កៈ ចាបង!!!
ខៈ ហើយដល់ពេលសព្វថ្ងៃនេះអី!!! បើថាអាឡោះអាឡៃគ្នាអី!!!
គេមិនដេលថាខលមកទេ។ ចង់ទៅលេងគេអីគាត់ថាពួថាយាយឈើហាស់។
កៈ ចាបង!!
ខៈ ខ្ញុំក៏ថាពុកឯងចង់ទៅលេងគេ!! ប៉ុន្ដែគេមិនដែលនឹងនឹករលឹកពុកេងផង។
ចង់ឃើញថាដើរទៅជិតគេ!! គេឃើញយើងគេដើរគេចទៅឡើងឆ្ងាយ។
កៈពួកគាត់ចាស់ហើយ។ ម៉េចក៏គាត់ដាច់បិត្ដម្ល៉ះ?
ខៈ នឹងហើយ!!! បុណ្យកាលភ្ជុំ!! គា! គាត់ឃើញ!! គាត់បំរុងដើរទៅសួរចឹងហាស់។
យាយ!! ដើរទៅចឹងហាស់។ ដើរទៅមិនទាន់នឹងដល់ផង។
យាឃើញ!ដើរគេចទៅនោះបាត់។ គាត់ធ្វើដូចមិនដែលស្គាល់យើងហាស់!!!
កៈ ចាបង!!
ខៈខ្ញុំក៏ថា!!ពុកឯងដើរទៅអង្គុយជិតគាត់ធ្វើអីទៀត។
បើគេមាននិស្ស័យនឹងយើងមែន។
គេមិនមែនដើរគេចយើងដូចសត្វប្រលោតទេ។
កៈចាបង!!
ខៈ ហើយចាប់តាំងពិថ្ងៃនឹងមកគាត់ដាច់បិត្ដហើយ។
កៈ ចា!! អញ្ចឹងឥឡូវឳពុករបស់បង! តើគាត់នៅឯណា?
ខៈ នៅនឹងផ្ទះនៅខាងឈើទាល!!!
កចា!!!
ខៈ តែគាំត់ឥឡូនេះវគាត់ជរាហើយ។ ភ្នែកគាត់មើលរៀងស្រវាំងដែលហើយ។
ចុះគាត់៨០ឆ្នាំជាងទៅហើយនឹង។
កៈ ជាបង!!
ខៈ គាត់៨៥ឆ្នាំហើយណា!!!
កៈ ចបង!!
អញ្ចឹងតើពេលដែលគាត់បែកគ្នាជាមួយម្ដាយរបស់បងចុងរបស់បងឯងគាត់កាលនឹងគាំត់មានអាយុប៉ុន្មានណហើយ?
កាលនឹងគាត់ការជាមួយគ្នានៅក្មេងដែលតើហី?
ខៈ ទេ!! ពួកគាត់ទឹមតែបែកគ្នាបានពីរឆ្នាំនេះឯង។
ម៉ែខ្ញុំខូចបានប្រហែលជាមួយឆ្នាំ។
កៈ ចាបង!!
ខៈ គាត់និយាយប្រវត្តិរបស់ឳពុកខ្ញុំអោយខ្ញុំស្ដាប់។ តាមប្រវត្តិគាត់ហាស់!!!
ពេលដែលម្ដាយរបស់ខ្ញុំខូចគាត់យំអោបហាស់!!
កចាបង!!
ខៈ ហៅសុទ្ធតែអូនបង!!! អូនអែងស្លាប់ចោលបងហើយ!!!
អូនឯងស្លាប់ចោលបងហើយ!!! យំអោបខោបហោ! ម៉ែខ្ញុំឈ្មោះទូចហូ!។

ក៖ ចាបង!!!
ខ៖ អូនឯងស្លាប់ចោលបងហើយ!! អូនឯងស្លាប់ចោលបងហើយអីណា។
យំតាំងនោលហាស់!!!
ក៖ ចាបង!!!
ខ៖ ចា!! បើតាមតែគាត់យំ!
គាត់អត់ស្រេនថាយកប្រពន្ធមួយទៀតទេតាមដែលយំហាស់។
គាត់ដេកអោបខ្មោចទាំងយប់ហាស់។
ក៖ អូចា!!!
ខ៖ អ្នកណាយកខ្មោចទៅណាអត់បានទេ!! យំហូរៗដូចមនុស្សស្រីអញ្ចឹងឯង។
ក៖ ចាបង!!!
ខ៖ ដល់ម៉េខូចះអស់បានប្រហែលជាប្រាំខែហាស់!! ទាចង់បានប្រពន្ធមួយទៀត។
ហើយដល់ពេលចឹងទៅ។ បានដូចជាអ្វីដែលម៉ែខ្ញុំគាត់ថាហាស់!!
យីអាមនុស្សប្រុសវាចាំរោរអញ្ចញចឹងមែន។ ម៉ែដែលចិញ្ចឹមខ្ញុំសព្វថ្ងៃនេក។
ក៖ ចាបង!!!
ខ៖ ជីដូនមួយឳពុកខ្ញុំនឹងគាត់ថា!!
ដេកអោបខ្មោចនឹកនាណាស់។ស្រេនតែដប់ម្ភៃឆ្នាំបានទារកប្រពន្ធ!
ហើយនេះប្រពន្ធស្លាប់មិនទាន់បានមួយឆ្នាំផង។ ទារកប្រពន្ធទៀត!!
ហើយនេះមិនទាន់នឹងបានកន្លះឆ្នាផងទារកប្រពន្ធមួយទៀតបាត់ហើយ។
ក៖ ចាបង!!!
ខ៖ ហើយរំលងបានប្រហែងជាមួយឆ្នាំ! គាត់ទៅស្តៅហាកាលនឹង!
កាលនឹងគាត់ជិះកងទៅ។
កាលនឹងយើងមិនទាន់មានឡានជិះកាលនឹងយើងទៅរកអីយលងជិះកង់ហាណា
អ្នកគ្រូកាលនឹង។យើងមិនទាន់មានឡានម៉ូតូជិះណាកាលនឹង។
ក៖ ចាបងនឹងហើយបង!!
ខ៖ បើដើមបើមានកំថាឡើយម៉ូតូ!!!
មានតែកង់កញ្ចាស់មួយក៏គេហៅថាអ្នកមានហើយ។ ល្មមហើយនឹង!!!
ក៖ ចាបង!!!
ខ៖ ហើយគាត់ក៏ទៅរកសុីនៅស្តៅក៏ជួមជាមួយនឹងយាយនឹងហាស់!!
ក៖ ចាបង!!!
ខ៖ ដល់ពេលជួបគ្នាទៅយាយនឹងគាត់ក៏មេមាយដែល!! ចា!!
ប៉ុន្តែគាត់មានកូនចិញ្ចឹមរបស់គាត់មួយថា។
ដល់ពេលចឹងទៅគាត់ក៏មេមាយដូចគ្នា! គាត់សុខចិត្តរៀងខ្លួន!!!
ក៏ផ្សំផ្គុំអោយគាត់យមគ្នាទៅ។
ហើយបានសែនអីអោយពួកគាត់បានត្រឹមត្រូវចា!!!
ក៖ ចាបង!!
ខ៖ ពេលសែន្ទំទៅហាស់!!!
ក៖ ចាបង!!
ខ៖ ហើយបងប្អូនរបស់ខ្ញុំអីទៅចូលរួមពីនេះដែលទៅជុំគ្នានឹងទៅ។
ក៖ ចាបង!!!
ខ៖ រួចទៅគាត់ក៏មកនៅខាងខ្ញុំឯនេះវិញ។ នៅជាមួយនឹងបងខ្ញុំនេះហាស់។
ក៖ ចាបង!!
ខ៖ ហើយនៅជាមួយគ្នាមិនទាន់បានប៉ុន្មានឆ្នាំផងឈ្លោះគ្នាជាមួយបងប្រុសខ្ញុំ។
គាត់មកនៅមិនទាន់បានប៉ុន្មានឆ្នាំផង។ ដូចថាគាត់មកក្តោបក្តាប់របស់ហាស់?
ក៖ ចាបង!!
ខ៖ ឳពុកេបស់ខ្ញុំគាត់ដៃត្រជាក់។ បើដាំក្រូចអីវិញ! ផ្លែឡើងល្អ។ ត្រឡាច! ស្ពំ!
ឡាពៅដាំនឹងតែផ្លែហើយ។ ចា!! ហើយយាយគាត់ជាអ្នកប៉ះលក់ប៉ះលក់។
ហើយខ្ញុំនឹងបងប្រុសខ្ញុំប៉ះអត់បានទេ។

កៈ ម៉េចចឹងបង?
ខៈ ចុះយើងអាងតែជារបស់ពុកយើង! យើងទៅប៉ះ។
ហើយគាត់ហួងហែងហាស់។ហើយគាត់ ឈ្លោះជាមួយខ្ញុំជាមួយបងប្រុសខ្ញុំ។
ហែងងែងមកប៉ះរបស់អាញ់។ ចេះចុះគាត់ថាអោយយើងហាស់។
កៈ អូចា!!! ខ្ញុំស្មានតែបងទៅដាំនៅនឹងដីរបស់គាត់។
ខៈ ចា!! គាត់អាងសិទ្ធិជាប្រពន្ធគាត់មកថាអោយយើង។
តែដីមិនមែនជាដីរបស់គាត់ទេ! ដីដីរបស់ខ្ញុំមិនមែនដីរបស់ម៉ាកឯងទេ!
ជាដីរបស់ខ្ញុំជាមួយបងប្រុសរបស់ខ្ញុំហាស់។
កៈ ចាបង!!
ខៈ គាត់ខឹងជាមួយនឹងបងប្រុសរបស់ខ្ញុំ!!
ហើយគាត់ក៏រត់ទៅនៅនឹងជ្រោងស្តៅនោះវិញទៅ។
កៈ ចាបង!!
ខៈ ហើយឪពុកខ្ញុំគាត់ក៏ទៅតាមទៅ។
កៈ ចាបង!!
ខៈ ហើយដីនឹង! គាត់ក៏ឈប់កាន់កាប់ទៅ។ អោយទៅបងរបស់ខ្ញុំទៅ។
ហើយដីនឹងគាត់ឈប់យកអីតាំងអស់!!។
កៈ ចាបង!!
ខៈ ដល់ពេលតាំងតែពីមានរឿងនឹងមក!! យើងក៏នឹកឃើញ។
យូរៗទៅលេងពុកយើងម្តងទៅណាស់។
កៈ ចាបង!!
ខៈ មួយឆ្នាំ! ពួកយើងបានទៅលេងគាត់តែពីរដងទេ។ ភ្ជុំហើយនឹងចូលឆ្នាំ។
កៈ ចាបង!!
ខៈ ខ្ញុំមិនដែលទៅលេងគាត់ទេ!! ហហើយកាលដែលឈ្លោះគ្នាពីរឆ្នាំនឹង។
ខ្ញុំមិនដែលបានទៅលេងគាត់ទេ។
កៈ ចុះឥឡូវនេះតើពួកគាត់បានលែងឡូះគ្នាមែនតែនហើយតើហីបង?
ខៈ ចា!! ពួកគាត់ដាច់គ្នាមែនទែនហើយ។ គាត់មិនដែលនឹកនាយើងផង។
តែបើយើងនៅតែនឹកគេហាស់!!!
កៈ ចាបង!!
ខៈ ពេលឮគេប្រាប់ថាយាយនេះឈើចេះចុះអីទៅអើត។ ខ្ញុំប្រាប់ថាពុកឯង។
គេមិនដែលនឹកយើងផងពុកឯងទៅនឹកនាអីគេទៀត។ អោយអស់និស្ស័យទៅ!!
វ័យប៉ុននេះហើយណាពុក។ កាន់ជមកាន់អានឹកឃើញទៅមុខឯនុះ។
កៈ ចាបង!!
ខៈ
បើសិនជាគេនៅអាឡោះអឡៃជាមួយយើងគេមិនដេញយើងមកផ្ទះតាំងថ្ងៃអញ្ចឹង
!!! ខ្ញុំអោយគាត់អញ្ចឹងហាស់។
កៈ ចាបង!!!
ខៈ ហើយដល់ពេលអញ្ចឹងទៅនៅស្ងៀមអត់ហានត!!!
កៈ អញ្ចឹងយាយដែលត្រូវជាម្តាយចុងរបស់បងគាត់អត់មានតាអីទៀតទេណេះ???
ខៈ គាត់អត់មានទេ។ ដាច់ត្រឹមគាត់នឹងឯង។
កៈ ចា!! ល្អដែល!
ដោយសាគាត់បែកគ្នាពីឪពុករបស់បងហើយបើគាត់ទៅយកអ្នកផ្សេងទៀតបាន
ថានេះ? នេះគាត់អត់អីដែល។
ខៈ ទោះបីជាគាត់តោយកអ្នកផ្សេងក៏គាត់នៅមិនសុខដែល។
បើយកអត់សុខទេ!!
កៈ គាត់ម៉េចបង? គាត់ឆ្នាស់ហីបង?
ខៈ យាយនឹងគាត់កាច។ គាត់កាចបាដោយយាយទៅ!!!
កៈ ហើយចុះតើគាត្រ់ឡាញ់បងឯងដែល? គាត់ស្រឡាញ់បងឯងអីជម្មតាតើហី?

ខ៖ ពីមុនអីគាត់ស្រឡាញ់ខ្ញុំរាប់អានអីចម្កតាតើ។
ពីដើមអីគាត់មកគាត់ចូលមកលេងខ្ញុំះដែលតើ។
ក៖ ចាបង!!
ខ៖ គាត់មកលេងបាត់ដំបងមិនចេះតិចដងទេអ្នកដែលឃើញហាស់។
ក៖ ចាបង!!!
ខ៖ តែគាត់អត់ចូល!!!
ក៖ ចាបង!!
ខ៖ ទៅលើនោះអីក៏គាត់អត់ចូលដែល។
អ្នកផ្ទះជិតនឹងគាត់មកគាត់ចេះចូលលេងគេ។
តែផ្ទះឪពុករបស់ខ្ញុំអត់ចូលទេហើយផ្ទះរបស់ខ្ញុំពីផ្ទះ។
ហើយខ្ញុំក៏មិនខ្វល់គាត់មិនចូលក៨ហីទៅចុះ។
ក៖ ចាបង!!
ខ៖ ហើយដោយសារតែយើងអត់មាននិស្ស័យបងប្អូនអីជាមួយនឹងគាត់ណា៕
បើមានកូនខ្លាចគ្រាន់មាននិស្ស័យហាស់។
ក៖ ចាបង!!
ខ៖ នេះអត់មានកូនមានអីជាមួយគាត់ណា!!
ហើយគាត់ធ្វើដល់ម្លឹងដាក់ឪពុករបស់យើងហើយ។
ក៖ ចាបង!! តេមិនអីទេចាប់ហើយ។ ចប់ទៅក៏វាល្អដែល!!!
ខ៖ ចាចា!!!
ក៖ អញ្ចឹង! ឥឡូវសួរកាលពីបងនីរៀនវិញម្តង៕
ខ៖ ចា!!!
ក៖ អញ្ចឹងកាលបងនៅរៀនតើបងមានលុយទៅសាលារៀនចម្កតាតើហី???
ខ៖ កាលខ្ញុំនៅរៀន។ សម័យនឹងវាមិនមាអីនណាស់ណាទេអ្នកគ្រូ។
ដូចថាសម័យនឹងយើងមានលុយទៅរៀនអីគ្រាប់គ្រាន់ហាស់!!!
ក៖ ចាបង!!
ខ៖ ខោអាវស្លៀកពាក់អីមានសមរម្យដុចគេដូចឯងដែលចា!!
លុយកាក់ចាយវាយអីមានសមរម្យសំរាប់បាយដែល។ គ្រាន់តែថាជាក់។
ដល់ពេលយើងវារបល់ច្រើនទៅ។ អាការរៀនសូត្ររបស់យើងនឹងវាមានតិច។
យើងអត់សូវមានពេលសំរាប់រៀនទេចា!!!
ក៖ ចាបង!!
ខ៖ ចា! ដោយសាតែដំណាំយើងវាច្រើនហូចា!!!
ក៖ ចាបង!!
ខ៖ ចា! ដោយសាតែពុកម៉ែរបស់យើងគាត់ជាអ្នកដាំដុះចា!
ដំណាំដំណោចស្រែចំការ! ល្ហុត។ ខែក្រូច! ប៉ះលក់! លក់រហូតគ្រប់រដូវ។
ក៖ ចាបង!!
ខ៖ អញ្ចឹងពេលវេលារបស់យើងមកតែពីរៀន។
អត់មានបានទៅរៀនសូត្រអីនឹងគេប៉ុន្នានទេ!!
មកតែពីរៀនទៅទៅថធ្វើការទៅច្រូតស្មៅគោ។ ហោកដល់ម៉ោងទៅរៀន!!
ពេលមកពីរៀនវិញទៅទៀតហើយ។
នៅពេលដែលសំរាកពីរៀនអីអញ្ចឹងដឹងតែធ្វើការ!!ចា! លក់រហូត! អញ្ចឹងហាស់! ។
ដល់ពេលងញ៉ឹអ ទៅអាខួរក្បាលវក់នឹងអារបស់នឹងហាស់។
ដល់ពេលអញ្ចឹងទៅយើងវាអត់សូវមានពេលសំរាប់ទៅរៀនសូត្រ។
រៀនសូត្រយើងអត់មានពេលរៀន។
តែលុយកាក់អាចមានសំរាប់ទៅសាលារៀនអីបាន។
ក៖ ចាបង!!
ខ៖ គ្រួសារអត់អីទេ!!!
ក៖ ចឹងគ្រួសាររបស់បងមានជីវភាំពអីដូចាចម្កមតាទេគ្រួសាររបស់បង?

ខៈចា!! អត់អីទេ។ ជីវភាពធូធាធម្មតាទេ!! គ្រាន់តែថាវាមិនធូធាអីណាស់ណាទេ។ គ្រាន់តែថាវប៉ុននឹងវានៅកណ្ដាល។
កៈ ចាបង!!
ខៈ គ្រាន់តែថាជីវិតគ្រួសារយើងអ្នកស្រុកស្រែវាតែប៉ុននឹងឯងយើងគ្រាន់។
កៈ ចា!! នឹងហើយបង!
ហើយចុះកាលដែលបងរៀនបងបានរៀនដល់បឋមសិក្សាឬក៏វិទ្យាល័យអីដែលអត់???
ខៈ ខ្ញុំចូលរៀនបានដល់ថ្នាក់ទី១០!។
កៈ អានឹងគេហៅ!!! អនុហើយនេះ??អនុហើយ!
ខៈ ចានឹងហើយ! បើយើងសព្វថ្ងៃយើងហៅថាអនុហាស់!!
កៈ ចាបង!!
ខៈ ទី១០! ពេលដែលខ្ញុំប្រឡងរួចខ្ញុំ!ឈប់រៀនបាដោយ។
ខ្ញុំប្រឡងនៅនឹងភ្នំសំពៅយើងនែក។
កៈ អូ!!! បងបទៅប្រឡងដល់ភ្នំសំពៅ?
ខៈ ចាប្រឡងរួចខ្ញុំឈប់បាដោយ!! ប្រឡងរួចាប់ទៀតណាកាលនឹងហាស់។
កៈ ចាបង!១
ខៈ កាលនឹង! កាលខ្ញុំប្រឡងនឹង។ គឺរដូវគេប៉ះស្វាយប៉ះក្រូច។ នែកខែនេះឯង។ ក្រូចស្វាយកំពុងពេញផ្លែហាស់!! លក់ៗព្រោះអីវាច្រើនហូ!!!
កៈ អូចា!!!
ខៈ ហើយើងរៀនទៅប្រឡងកាលនឹង។ យើងជាប់! តែយើងបានអាលេខចុងក្រោយគេហាអ្នកគ្រូ!!
ដូចជាបានកំរឹតសេអញ្ចឹចងហាស់។
កៈ អូបងបាននិទ្ទេសសេ?
ខៈ ចា!!
កៈ និទ្ទេសសេល្អហាណាបង!!!
ខៈ ហេ!!! ក្រោយគេហាស់!!
កៈ អត់ទេនិទ្ទេសអើតើបានក្រោគេបង្អស់៕
ខៈ ABC! អន់ជាងគេហី?
កៈ អត់ទេE បានអន់! ។ ក្រោយគេ!!
ខៈអញ្ចឹងហី?
កៈ ចាបង!! នឹងហើយ!។
ខៈ អញ្ចឹងបានកំរឹតគ្រាន់បើនឹងគេដែលហាស់!!
កៈ ចា! ហាហា។
ខៈ អញ្ចឹងទៅ! ម៉ែក៏ថាឈប់ក៏ឈប់ទៅ។ យើងវារ៉ក់រឺច្រើនមុខពេក! ម៉ែគាត់ថារៀនទៅយងវាបានចេះអក្សរហាស់!
ហើយយើងវាបុរាណមានបានទៅគិតអីច្រើនវែងឆ្ងាយកាលនឹងហាសអ្នកគ្រូ។
កៈ ចាបង!!
ខៈ រៀនអោយតែបានចេះអក្សរ!! កុំអោយតេមើលអក្សរមិនដាច់ទៅបានហើយ។ ម៉េខ្ញុំគាត់ថាអញ្ចឹងហាស់កាលនឹង។
កៈ ចាបង!!
ខៈ ហើយអាយើងកជឈប់! ឈប់ដែលទៅ។ ហើយឈប់ទៅក៏ឈប់រហូត។ ហើយការងារវ៉ក់រឺ!! ចុះដូចខ្ញុំបាននិយាយចឹង។ ចុះមានមនុស្សណា! មានទេយើងមួយនឹង។
កៈ ចាបង!!
ខៈ បើសិនជាមនាប្រុសមានស្រីចេះតែជំនួសគ្នាហើយ!។
កៈ ចាបង!!

ខ៖ចា! តែវាអត់មាន។ បងប្អូនខ្ញុំមានតេពិតមែន!! តែពួកវានៅរៀន។
ដល់ពេលនៅរៀន! ហើតគេនៅជាមួយគ្រួសារផ្សេងទៅ! គេម៉េចមកជួយយើង។
ក៖ ចាបង!!
ខ៖ ចា!! ហើយម៉ែរបស់ខ្ញុំគាត់នៅនោះ! គាត់មានកូនមកពីណា?
អត់មានកូនពេលយើងនៅជាមួយត្រូវតែយើងនឹងឯង។
ក៖ ចាបង!!
ខ៖ អញ្ចឹង! រ៉ក់រីនឹងការងារច្រើនវាខាត។
ក៖ ចា! អញ្ចឹង។ នៅក្នុងគ្រួសាររបស់បងបងជាកូនទីពីរមែនដែលអត់?
ខ៖ ចាទីពីរ!!
ក៖ អញ្ចឹង! តើអ្នកណាមានគ្រួសារមុនគេ? កូនបងមែន?
ខ៖ បងខ្ញុំ!
ក៖ចឹងបន្ទាប់មកបងឯង?
ខ៖ ចា!! បន្ទាប់មកខ្ញុំ។
ក៖ ចឹងបន្ទាប់មកបង! ហើយបន្ទាប់មកប្អូន?
ខ៖ ចំមើល! មុនដំបូងបងខ្ញុំ! ហើយបានមកប៉ុន្នានខ្ញុំ!
ហើយបានប្អូនស្រីខ្ញុំមួយទៀត។
ក៖ អញ្ចឹងតាមដំណាក់កាលហីបង?
ខ៖ ចានឹងហើយ!!
ក៖ អូ!! ល្អដែលតើបង។
ខ៖ ប្អូនពៅរបស់ខ្ញុំមានកីនពីរហើយ!!
ក៖ ចាបង!!
ខ៖ កំខ្ពស់ៗនេះ។
ក៖ អញ្ចឹងពីរដូចបងឯងដែល?
ខ៖ ចា!! អត់តែបងខ្ញុំគេប្រាំ!!!
ក៖ ចា!! អញ្ចឹងសាលាដែលបងរៀននឹងឈ្មោះអីគេ? ហើយនៅកន្លែងណាដែល?
ខ៖ សាលារៀនឈើទាលបាដោយ!
ក៖ អូ!!!
ខ៖គេហៅអនុវិទ្យាល័យឈើទាល! មានបឋម!
មានតាមថ្នាក់ដូចយើងនៅអូដំបងនេះដែលហាស់។
ក៖ ចាបង!!
ខ៖ តែសលារៀនគេធមដែលហាស់នៅនឹងហាស់។
ក៖ ចាបង!!
ខ៖ ចា!!
ក៖ អញ្ចឹងបងកើតមកធ្វើចំការនេះបងនេះ??
ហើយដល់រហូតមកឡូវនេះក៏នៅតែធ្វើចំការដែលបងនេះ?
ខ៖ ហឺ!! នៅតែគេចមិនផុត។ ពូជអ្នកធ្វើស្រែចំការនៅជួបចឹងអ្នកគ្រូ។
ក៖ ចា!! ខ្ញុំធ្លាប់ឮគេនិយាយចឹងដែល។ ពូជអ្នកធ្វើចំការ!!
មិនបាច់ខំគេចទៅណាទេ។ ក៏នៅតែធ្វើចំការ។
ខ៖ ចា! វានៅតែចឹងអ្នកគ្រូឯងមើល។
ក៖ ម៉េចបានវាចឹងណបង?ខ្ញុំក៏ឆ្ងលដែល!!!
ខ៖ អានឹងគេថាប្រហែលជាពូជហើយមែនននជអ្នកគ្រូ? ស្រែចំការស្រែចំការ!!!
ក៖ ចាបង!!
ខ៖ មិនថាប្ដីអីទេ!!ប្ដីរបស់ខ្ញុំគាត់មិនសូវវិញទេ។ ប្ដីខ្ញុំហាស់!!!
ក៖ ចាបង!!
ខ៖ រឿនស្រែអីអោយទៅធ្វើគាត់មិនចេះធ្វើទេ។ ស្រែបាចជីហាស់!!
អោយតែគេដឹកទៅអោយនឹងវាបុណ្យធំទៅហើយ។
ក៖ ជាបង!!

ខ៖ ហើយបើដឹកខ្លួនឯង! ឆ្លងប្រឡាយអីខ្លួនឯងចេះតែទៅៗ។
ពេលទំនេរអីបានគេដឹកអោយ។ គេដឹងអោយហើយគេទំលាក់ចោលព្រុស!
ហើយយើងនេះរ៉ែកឆ្លងកាត់ប្រឡាយម្តងមួយឡាំងម្តងមួយឡាំង។ ទឹកសុទ្ធតែភ្លក់!
វេទនាហាណាអ្នកគ្រូ។ ដកស្ទៅអីទៅ!!
ក៖ ចាបង!!
ខ៖ ចុះយើងនឹកឃើញថា! ជីវិតយើង។ ពេលដែលដឹងក្តីមកវានឿយរហូត។
ហើយទៅស្រែចំការទៅភ្លឺកាត់ទៅទៅកាប់ជ្រុងទៅ។ ហើយទៅមាន
ឫស្សីឯណាទៅកាប់ជ្រុងស្រែអ្នកគ្រូឯងគិតមើល?
ក៖ ចាបង!!
ខ៖ ទាល់តែគេមនុស្សទៅកាប់គ្រប់គ្នា!! ឯយើងវិញទៅកាប់ខ្លួនយើង។
ក៖ ចាបង!!
ខ៖ ហើយតាមរបងចំការអី! មិនអោយកាប់ម៉េច! វរធំៗវាឡើង។
ហើយប់យើងមិនកាប់វាវាមិនងាប់?
ក៖ ចាបង!!
ខ៖ វាមិនថាប់!! ហើយមិនអោយយើងមើលថែវាម៉េច?
ក៖ ចា!!
ខ៖ បើម៉ែឪយើងទុកអោយហើយ! បើយើងមិនមើលថែមិនប៉ះបោចមិចកើត!
មិនចឹងហេអ្នកគ្រូ?? វាត្រូវតែធ្វើ។
ហើយដំបូកស្រែទៅកាប់រំលាយទៅហើយពីរទៅបីថ្ងៃទៅ។ ទំរាំតែកាប់វារួច!!
ក៖ ចាបង!
ខ៖ មួយព្រឹកមួយសន្ទុះទៅ!! ដល់ម៉ោ១១តៅ១២បានមកដាំបាយអោយគេសីទៅ។
ហើយពេលល្ងាចទៅវិញទៀតទៅ។
ក៖ រហួត?
ខ៖ ចានឹងហើយ!! រំលាយដមបូក។ រហូតដល់អស់ដើមចារអស់មួយដើម។
កាច់រំលាយវា!! ចុះវាធំហ្វូ!!
ក៖ ចា! ហាហ។
ខ៖ ចុះវានៅកណ្តាលស្រែហូចា!!! កាប់អានឹងអស់មយយឆ្នាំចឹងទៅ។
បានទៅពាយអានុះមួយដើមទៀត។ ហាហា
ក៖ យ៉ា!!! ខ្លាំងផងណាបង!។
ខ៖ ហាហា!!! ចាអ្នកគ្រូ។ ហត់ហាណា។
ក៖ អញ្ចឹងមានន័យថាកិច្ចការស្រីប្រុសគឺនៅលើបងហើយនេះ?
ខ៖ ហឺ!! និយាយទៅជាក់! ប្តីរបស់ខ្ញុំគាត់ដូចជាំទៅល្ហមវិញ។ មែនហេ?
ក៖ ចាបង!!
ខ៖ គេអត់ខំទេ! គេដូចល្ហម។
ក៖ អញ្ចឹងបងហត់ជាងប្តីរបស់បង?
ខ៖ ចាងហត់ហត់ជាង។ ចាខ្ញុំហត់ជាងគាត់ឆ្ងាយណាស់។ ដឹងថាខ្លួនឯងហត់។
ក៖ ចា!!!
ខ៖ខ្ញុំមមិននិយយាអួតទេណាស់!!
ក៖ ចាបង!!
ខ៖ សាច់ការងារខ្ញុំហត់ជាងគាត់ឆ្ងាយ។ វា៨០%ហើយណាអាបន្ទុកនឹងហាស់!
ក៖ ចាបង!!
ខ៖ គេជាអ្នករកលុយមែនតែគេរក! គេរកតែមួយមុខហាស់។
ក៖ ចាបង!!
ខ៖ មកវិញគេសំរាកមានពេលដេកមើលទូរទូរស៏។ ដេកមើលទូរស័ព្ទ! គេសំរាក!
គេសុ៊ីផឹកបានខ្លះហាអ្នកគ្រូ។
ក៖ ចាបង!!
ខ៖ តែយើងអត់ទេ។ បើមិនអស់នេះអស់នោះ!!!

កៈ ចាបង!!
ខៈ ខ្ញុំជួនកាលយប់ម៉ោង១២មិនទាន់បានចូលដេកផង។
កៈ ចា!!
ខៈ នៅធ្វើដល់ម៉ោ១១ ១២រាល់ថ្ងៃ។
កៈ ធ្វើការរហូតដល់យប់?
ខៈ ចា!! ហើយបើមានពេលដេកនឹងមិនបានដេកទៀត។
កៈ ចា!! អញ្ចឹង!
ក្រៅពីការងារស្រែចំការបងឯងមានរកការងារអីផ្សេងពីនឹងធ្វើទៀតអត់ទេ?
ខៈ ពីមុនមក! កន្លងមកអត់បានធ្វើអីទេណាស់។
កៈ ចាបង!!
ខៈ ដល់ពេលចុលមកឆ្នាំនេះមក! យើងប្រកបការងារ។
ដូចថាយើងបានរៀនចូលជាសមាជិកក្នុងសាសន៏នាចក្រចឹង។
កៈ ចាបង!
ខៈ បានចូលរៀនជាមយយអង្គការចឹងទៅ!
យើងរៀនទៅយើងបានចំនេះដឹងទៅ។ យើងបានអាស្ទី? រៀនស្ទី? រៀនអាជីវកម្ម!
រៀនខ្លួនទីពឹងខ្លួន។
កៈ ចាបង!!
ខៈ អោយយើងយល់ដឹងចឹងហាស់។
កៈ ចាបង!!
ខៈ អោយយើងតស៊ូក្នុងជីវិត។ អោយយើងពឹងខ្លួនយើង។
កុំអោយពឹងអ្នកដទៃហាស់!!
កៈ ចាបង!!
ខៈ អញ្ចញចឹងបានថា! ខ្ញុំធ្វើអីសព្វថ្ងៃនេះ។ ខ្ញុំពឹងខ្លួនឯងទាំងអស់។
ខ្ញុំពឹងកំលាំងគេតចណាស់។
កៈ ចាបង!!
ខៈ ខ្ញុំគិតថានឹកឃើញថាគេធ្វើកើត។ រឿងធីដែលថាយើងធ្វើមិនកើត។ ចា!
កៈ ចា!!
ខៈ យើងជាំមនុស្សដូចគេដែលយើងតស៊ូ! ទាល់តែខ្ញុំទៅមិនរួចបានខ្ញុំប្រើគេ។
កៈ ចាបង!!
ខៈ ប្តីក៏ដោយ។
កៈ ចា!!
ខៈ ខ្ញុំប្រើគេតេមួយដង។ បើគេមិនធ្វើទេ!! ខ្ញុំធ្វើខ្លួនឯងហើយចា!
ខ្ញុំលើកលីមិនរួចបានខ្ញុំប្រើ! អញ្ចឹងខ្ញុំពឹងខ្លួនខ្ញុំ! ខ្ញុំធ្វើបានតែវាប៉ុនណឹងហាស់!!
កៈ ចាបង!!
ខៈ អញ្ចឹងបានថាខញ្ញុំវាចេះតែនឿយហាស់ម្នកគ្រូ។
កៈ ចាបង!!
ខៈ គេមិនសូវចេះ។ គេមិនសូវនឿយ! យើងវាចេះយើងវានឿយហាស់ចា។
ដលើពេលយើងទៅរៀនសូត្រទៅបានអង្គការជយយយើងអោយចិញ្ចឹមមាន់ចិញ្ចឹម
អីកាលចូលឆ្នាំនឹងហាស់។
កៈ ចាបង!!
ខៈ បើកំរិតជីវភាព។ ថាធូជាងមុន! វាមិនណាស់ណាទេ! វាកាត់បន្ថយ។
កៈ ចា! ជួយបានមួយកំរិត។
ខៈ ចា! វាកាត់បន្ថយ។ បើទៅមុខវាចិញ្ចឹមកបទៅ។ វាអាចធូជាងនឹងហាស់។
កៈ ជាបង!!
ខៈ ចា!! អញ្ចឹងខ្ញុំអរគុណដល់អង្គការដែល! ដែលបានជួយដល់ខ្ញុំ។
កុំអីពិបាកដែលនឹងហាស់។ យើងទៅរកដើមទៅដាក់ធ្វើអានឹងវាមិនបានហាស់។
អាណារោងអាណាចំណីមាន់? វាគ្រប់មុខ។

កៈ ចាបង!!
ខៈ បានគេជួយប៉ុននឹងទៅយើងវាផ្សំគ្នាទៅណាស់។
កៈ ចាបង!!
ខៈ ផ្សំពីនវពីនោះទៅ។ ហើយសព្វថ្ងៃមិនអោយខ្ញុំគោរកសីម៉េច??
ចាំលុយប្តីគេអោយយើងម៉ែន!ដប់ថ្ងៃនបានគេបើកប្រាក់ខែ។
បើកមកជួនកាលគេសល់! ជួនកាលទោគេថាមិនសល់។
ហើយគាត់គ្មានលុយអោយយើងទេ។
កៈ ចា!!
ខៈអ្នកគ្រូ! ខ្ញុំនិយាយការពិតថ្ងៃស្មើនេះហាស់!!
កៈ ចាបង!!
ខៈ ខ្ញុំមិននិយាយកុហក់ទេ! អោយទៅសួរគាត់ចុះ។ បើថាខ្ញុំចេះតែថា!!
កៈ ចាញមជឿហើយបង!
ខៈ នៅពេលដែលសួរគាត់! គាត់ថាអស់លុយបាត់ហើយ។
ហើយខ្ញុំមនលុយអោយអស់បាត់ហើយ។
កៈ ចាបង!
ខៈជួមកាលគេបើកលុយមកសល់គេទុកអោយខ្លះ។ គេទុកនៅនឹងខ្លួនគេខ្លះ!
ហើយយើងចាយសីរាល់ថ្ងៃ។
កៈ ចា!!
ខៈ ហោកអាណាថ្លៃទឹក! ថ្លៃភ្លើង។
អានេះយើងអត់និយាយអាថ្លៃជួលផ្ទះគេទេណាស់អានឹងហា។
កៈ ចាបង!!
ខៈ ខ្លួនយើង!! ហើយនៅម្ហូបសុ៊ីរាល់ថ្ងៃ! ថ្នាំសង្កូវ! កុនលេបមយយខែពីរដង។
កៈ ចាបង!!
ខៈ ថ្នាំវាមួយខែ៣០ទៅ៤០៛ថ្នាំវាហាស់។ អាណាថ្នាំកូនផ្សេងថ្នាំឪផ្សេង។
អាណាចាក់សាំងម៉ូតូរាល់តែថ្ងៃចា។ហើយនឹងចំណីមាន់រាល់តែថ្ងៃ!
ហើយមិនអោយខ្ញុំទៅលក់មិច?? ហើយក្នុងមួយថ្ងៃ!
ក្នុងមួយព្រឹកបើចំណេញវិញពីរទៅ ៣,០០០០៛។ យ៉ាងងតិចហាស់! ២,០០០០៛
ទៅ៣,០០០០៛! ក្នុងមួយព្រឹកហាស់។ យ៉ាងអន់ ២,០០០០៛ ទៅ ៣,០០០០៛។
បើថ្ងៃណាតិចហាស់។
កៈ ចាបង!!
ខៈ បើថ្ងៃណាអីវ៉ាន់ខ្ញុំច្រើនខ្ញុំលក់បាន ៤,០០០០៛។ លក់ច្រើនមុនហាស់៕
កៈ ចាបង! បានគ្រាន់បើដែល។
ខៈចា! ហើយមិនអោយខ្ញុំគោលក់មិច?! គឺថាដើម្បីបានលុយនឹងយកទៅទិញម្ហូប!
ថ្លៃកណ្តក់វាផង! រាល់ថ្ងៃខ្ញុំអស់មយយថ្ងៃ ១,០០០០៛។
កៈ ចាបង!!
ខៈ កណ្តក់និងចំណីកូនមាន់នឹងហាស់! មួយថ្ងៃ ១,០០០០៛។
ហើយបើយើងមនលក់វាត្រូវបេញហើយ។
ហើយបើយើងអត់មានយកលុយអីទៅចេញ?
កៈ ចាបង!!
ខៈ អញ្ចឹងបើខ្ញុំបានទៅលក់! វាអត់សល់ទេលុយនឹង។
កៈ ចាបង!!
ខៈ វាអត់សល់ទេអ្នកគ្រូ!
តែខ្ញុំលក់សព្វថ្ងៃនឹងដើម្បីយកលុយនឹងទៅទប់នឹងមាន់នឹង។
កៈ ចាបង!!
ខៈហើយឃើញខ្ញុំលក់វាន់ថ្ងៃនឹង!ខ្ញុំប្លូរដែលហាស់អ្នកគ្រូ។
កៈ ចាបង!!

ខះ ហើយចិត្តគេហាអ្នកគ្រូ!! ខើញយើងទៅលក់គេមិនទ្រូតអរអីប៉ុន្មានទេ។
នេះខ្ញុំប្រាប់អ្នកគ្រូហាស់។ ខ្ញុំទៅលក់នេះទៅលក់ទាំងបង្ខំដែលទេ។
បើយើងមិនធ្វើ! វារកអាក់រៃនឹងទប់វាមិនឈ្នះ។
កះ ចាបង!!
ខះ ចា!! គេថាលក់មាន់ៗ។ មិនដឹងថាយកលុយទៅណាំអស់។
លក់ៗខំទេលក់កក់ៗប្រយ័ត្ន។ ចុះអាលក់មាន់លក់តាយកទៅទុកឯណា។
កះ ចាបង!!
ខះ គេថាអោយយើងអញ្ចឹង។ ខ្ញុំថាយើងលក់! យើងលក់យើងទុកខ្លះ!
យើងមិនមែនយកលុយទាំងអស់នឹងទៅទិញចំណីវិញទាំងអស់ទេ។
កះ ចាបង!!
ខះ យើងវាចង់បានលុយបន្ថែមបីខាងក្រៅយកទៅទិញវា។
ដើម្បីអោយលុយអាយើងលក់បាននឹងសល់។
កះ ចាបង!!
ខះ ហើយបើឯងតៅលក់យកលុយទៅទិញអស់ដដែលៗវាបានប្រយោជន៍អី??
វាអស់តែលុយដដែលៗនឹងវាមែនមិនមេនអ្នកគ្រូ?
កះ ចាបង!!
ខះ ចា!! វាហត់នឿយ! ហើយលក់អញ្ចឹងវាខាតពេលវេលាគេ!
គេធ្លាប់តែទៅធ្វើការនៅម៉ោង ៨ព្រឹក! ហើយឡូវម៉ោ ៩ បានគេទៅធ្វើ។
គេអាឡូសតែជួយដាក់បាយមាន់ទាយើងពីប្រលប់ហូ?
កះ ចាបង!!
ខះ ពេលព្រឹកឡើងមាន់វាមិនត្រូវការសី?
កះ ចាបង!!
ខះ អញ្ចឹងវាខាតពេលវាលាគេវាអស់មួយម៉ោងចឹងហាស់។
កះ ចាបង!!
ខះ ហើយពេលមកខ្ញុំទិញម្ហូបស្រាប់យកមកហូប។ គេថាសីវាមិនឆ្ងាញ់!
សីវាមិនទៀងពេល៕
កះ ចាបង!!
ខះ គាត់ខឹងនឹងយើងចឹងហាស់!!!
កះ ចាបង!!
ខះ ហើយគាត់អត់ដឹងថាយើងដើបទៅពីយប់នឹងហាស់។
កះ ចាបង!!
ខះ ទៅផ្សារាល់ថ្ងៃ!!!
អត់ដឹងថាប្រពន្ធនឹងទៅដើរលេងឬក៏ទៅរកសីលក់ដូរអីអត់ដឹងទេ!!!
កះ ចាបង!!
ខះ ហើយបើថាឃើញចឹង! ប្រពន្ធដើបបៀតភ្លើ។ ហើយបើថាប្តីហើយទៅជួយលើក!
លើកដាក់ធូន់ប៉ុនណាក៏ដោយ។ ត្រូវដឹកពីរជើងបីជើងគាឯងអ្នកគ្រូ!!!
កះ ចាបង!!
ខះ ខ្ញុំមិនដែលប្រើទេណា!!
កះ ចា!!
ខះ សូម្បីតែកូនខ្ញុំក៏ខ្ញុំមិនដែលហៅដែល។ បើថធូន់ខ្ញុំខំប្រឹងលើក!!
ប៉ុន្តេឈឺអស់ហើយសរសៃ។
កះ ចា!! ហត់ហើយបងឯង។
ខះ ចា! ខ្ញុំចេះតែខំប្រឹងលើកទៅ។ នឹងឃើញថាបើហៅគេគេអត់ងងុយ។
បើហៅគេគេដើបទៅខ្យល់។ មានពិបាកអ្នកណាពិបាកយើងដដែលហូ?
កះ ចា!!
ខះ ចា!! ពិបាកអញ្ចឹងដដែល។ ខ្ញុំសុខចិត្តហត់នឿយតែឯងទៅ។
កះ ចាបង!! អញ្ចឹងតើបងដើបទៅលក់អីវ៉ាន់នៅម៉ោងប៉ុន្មាន?

ខ៖ ម៉ោងបួនខ្ញុំភ្ញាក់ហើយ។
ក៖ ម៉ោងបួនភ្ញាក់!!
ខ៖ ម៉ោងបួនខ្ញុំត្រូវតែទៅហើយ។
បបើយើងមិនទៅពីភ្លើយើងមានអីវ៉ាន់ឯណាអោយទៅគេ?ចា!
ក៖ អូ!!! បងឯងត្រូវទៅទិញអីវ៉ាន់ពីគេមកបានយកតោលក់?
ខ៖ ចា! ទិញពីគេមកបានយកទៅលក់។
ក៖ ហើយបងទៅទិញពីណាមកវិញ?
ខ៖ ខ្ញុំទិញនៅនឹងផ្សារថ្មីនឹងឯង។
ក៖ អូ!! អញ្ចឹងបាននៃថាបងឯងទិញនៅនឹងហើយលក់ក៏នៅនឹង? ចា។
ខ៖ ខ្ញុំទៅទិញនៅខាងមុខ! តែដល់ពេលខ្ញុំយកទៅលក់!
ខ្ញុំយកទៅលក់នៅខាងក្នុង។ ចា!
ក៖ អូ!! ឆ្លាតហាស់បង។
ខ៖ អញ្ចឹងហាស់! បើថាថ្ងៃណារៀងដាច់ទៅបាន ៤,០០០០៛ ទៅ ៥,០០០០៛។
ថ្ងៃណាទៅយ៉ាងអន់កដ៨ត្រឹម៣,០០០០៛ដែល។
ក៖ ចាបង!!
ខ៖ ទោះបីជាយើងវាមិនសល់ក៏ពិតមែន។ តែយើងបនចំណីមាន់!
ក៖ ចាបង!!
ខ៖ ធ្វើម៉េចអោយតែបានទប់អានឹងអញ្ចឹងហាស់។
ក៖ ចានឹងហើយបង។
ខ៖ បើតាមគេគេអោយយើងសិវាមិនគ្រប់ទេអ្នកគ្រូ។
តែយើងខំនឹងដើម្បីអោយវាឈ្នះវាសល់អានឹងហាស់ចា។
ក៖ ចាបង!!
ខ៖ បើយើងអាឡូតែបានមកយកអោយអានឹងអស់បានអីអ្នកគ្រូមែនហះ?
ក៖ ចាបង!!
ខ៖ ចា!!
ក៖ ត្រូវហើយបង។
ខ៖ ចា!!
ក៖ ប៉យើងមិនឆ្លៀតអញ្ចឹងទេមិនបានទេ។
ខ៖ ចាឆ្លៀត!! ខ្ញុំនឹកឃើញថាកូនខ្ញុំនឹងទាន់វារៀន។
ក៖ នឹងហើយ!!
ខ៖វានៅផ្ទះអញ្ចឹងអោយវាដាំបាយដាំអីសីទៅ។ ហើយយើងទិញម្ហូបមកពីផ្សារ។
ក៖ ចាបង!!
ខ៖ ដល់ពេលយើងទិញម្ហូបគេមក! គេថាស៊ីវាមិនឆ្ងាញ់។ ស៊ីមិនទៀតពេល!
ស៊ីទៅគ្មានជាតិជៅចឹងហាស់។
ក៖ ចាបង!!
ខ៖ ហើយចុះគាត់ទៅរកជាតិជៅ! ឆ្ងាញ់អីមកពីណា។ អត់មើលប្រពន្ធទេហី។
ហត់កក់ៗមករអ៊ូរអី!!
ក៖ ចាបង!!
ខ៖ ខ្ញុំក៏ប្រើបោកខោអាវម្តង។ មិនដែលទេណាស់។
ក៖ ចាបង!!
ខ៖ បោកបានពីរដងខ្ញុំទៅលក់មួយខែ។
ក៖ចា!!
ខ៖ គេថា!! យូរៗទៅខោអាវអោយឯងបោកខោអាវ!! ឯងដាក់ចំណីអោយហើយ!
អោយឯងបោកខោអាវទៀត។
ក៖ ចា!!

ខៈ ហើយខ្ញុំក៏ថា!! ហ៊ីប៉ា!
១៦ឆ្នាំហើយណាដែលប្រពន្ធបំម្រើឯងហាស់។ខ្ញុំថាអោយគាត់អញ្ចូងឯង។
ដាំបាយដាំទឹកបោកខោអាវ!! ហត់នឿយហាណាស់ប្រពន្ធដែលរអ៊ូរដែល?
កៈ ចា!!
ខៈ សួរខ្ញុំប៉ុនណឹងខ្ញុំថា។ ខ្ញុំដេកយំ! ខ្ញុំក្តៅហាណាអ្នកគ្រូ។
កៈ ចាបង!!
ខៈ ខ្ញុំហាស់! មិនដែលរអ៊ូថាហត់នឿយមិចទេ។ បៀតភ្លើខ្ញុំមិនដែលប្រើគាត់ទេ។
ហើយបើឯងហត់នឿយម្តងពីរដងអញ្ចឹងឯងរអ៊ូរ។
អញ្ចឹងបើឯងខ្លាចវាមានពេកមិនបាច់រកទេ។ មិនបាច់ធ្វើទេ!! ឈប់ធ្វើទៅ។
កៈ ចាបង!!
ខៈ គាត់ខឹងខ្ញុំថាអោយគាត់អញ្ចឹង!! ព្រឹកមិញ! អត់ជួយទេ។
កៈ ចា!!
ខៈគេថាអោយខ្ញុំសំដិគ្រាន់ដាក់គេ!! ខ្ញុំថាខ្ញុំមិនសំដិគ្រាន់ទេ។
ខ្ញុំនិយាយវាកាពិត។
កៈ ចាបង!!
ខៈ បើឯងខ្លាបប្រពន្ធវាមានបានពេក!! ខ្លាចមានបានពេកនឹង។
ខ្លាចខ្ញុំយកទៅអោយម៉ែរបស់ខ្ញុំឬក៏យ៉ាងម៉េច?ដែលខ្ញុំខំធ្វើរាល់ថ្ងៃខ្ញុំថាអោយគាត់ចឹងហាស់!!
កៈ ចាបង!!
ខៈ ឯងមិនបាច់ភ័យខ្លាច! ម៉ែខ្ញុំគាត់មានទៃអោយលុយខ្ញុំចាយវិញ!!
កៈ ចាបង!!
ខៈ កូនខ្ញុំកាលកំណើតលីសា! ខ្ញុំអត់មានលុយ។
ម៉ែខ្ញុំគាត់សុខចិត្តលក់មានអោយកូន។ អោយលុយហាស់! កំណើតកូនខ្ញុំលីសា។
ពេលកុនឈើម៉ែអោយលុយ។
កៈ ចា!!
ខៈ ហើយតើឯងដែលបានអោយលុយម៉ែដែល?
កៈ ចា!!
ខៈ ខ្ញុំថាអោយគាត់អញ្ចឹង!! ហើយរអ៊ូរថាហត់នឿយបោកខោអាវបួនប្រាំប៉ុននឹង។
ចុះត្រង់ខ្ញុំបំម្រើង១៦ឆ្នាំឯងដែលគិតដែល?
កៈ ចាបង!!
ខៈ បើគេចង់មានចង់បានអោយប្រពន្ធគេរកស៊ីទៅ។ ជួយគ្នាទៅ!
បើឯងគិតខ្លាចវាមានពេកអញ្ចឹងមិនបាច់ធ្វើទេ។ ខ្ញុំថាអោយគាត់ចឹងអ្នកគ្រូ។
កៈ ចាបង!!
ខៈ យប់មិញខ្ញុំដេកយំ! ព្រឹកមិញខ្ញុំក្រោកពីយប់ម៉ោងបី! ខ្ញុំភ្ញាក់ហាស់អ្នកគ្រូ??
កៈ ចាបង!!
ខៈ ខ្ញុំដាក់ចំណីមាន់អីស្រេច! ខ្ញុំដាក់ទឹកអីស្រេចបានខ្ញុំទៅលក់។
កុំអោយបិបាកព្រឹកឡើងអោយគេធ្វើទៀត។
កៈ ចាបង!!
ខៈ បើគេមិនជយយយើងហើយ! យើងទៅប្រើគេធ្វើអីទៀត?
កៈ ចា!!
ខៈ ខ្ញុំអត់ប្រើទេ!! ខ្ញុំខឹងខ្ញុំមិនដែលនិយាយទេ។ នេះខ្ញុំនិយាយការពិត។
កៈ ចានឹងហើយបង!!
មួយនឹងទាល់តែយើងចេះជួយធ្វើការងាគ្នាបានគ្រុមគ្រួសាយើងរីកចំរើនហាស់!។
ខៈ ចា!! របងផ្ទះនេះខ្ញុំថា! ខ្ញុំអត់ចង់ធ្វើទេ។ តែវាប្រហោងក្រហែងក្រហួង។
កូនយើងពេលយើងទៅលក់បាច់វានៅតែឯង។
កៈ ចា!!
ខៈ យើងខ្លាចអេចចាយវាចូលមក។ ចុះមកសព្វថ្ងៃនេះវាមកពីថៃវាច្រើនណាស់។

កៈ ចាត្រូវហើយបង!!
ខៈយើងខ្លាចវាចូលមកលុកលុយរបស់របបរយើង។
មាន់ទាយើងអីកូននៅតែឯង។
កៈ ចា!!
ខៈពេលយើងធ្វើរបងបាំងទៅណាស់។
ទោះបីជាវាមិនមាំទាំក៏វាបានការពារខ្លះហាស់។
កៈចា!!!
ខៈ ទោះបីជាយើងមកទាន់មិនទាន់អី។
វាបានពន្យាពេលខ្លះហាស់ពន្យាពេលចឹងទៅបានជាខ្ញុំចេះតែប្ដូរទិញទៅ។
កៈ ចាបង!!
ខៈ ហើយខ្ញុំអោយលុយគាត់ទៅទិញ ៥,០០០០០៛ ជាងចឹងហាស់។
ខ្វះប៉ុន្មានអីប៉ុន្មានគេថែមខ្លួនគេខ្លះទៅ។ ហើយក៏ធ្វើបានរបងប៉ុននឹងទៅ។
កៈ ចាបង!!
ខៈ គេថាប្រើឯងអស់លុយឯងទៀតគេថាអោយខ្ញុំអញ្ចឹង។ ខ្ញុំក៏ថាហ៊ឺ!!
កៈ អូ!!! អស់តិចដែលតើបង។
ខៈ ចា!! នេះយើងធ្វើខ្លួនយើងទេណាស់។
កៈ ចា!!
ខៈ ចាក់សសរអីខ្លួនឯងមិនបាច់រកគេទេ។ បើខ្វះឈើដាក់!
ដាក់អាឈើកំពេកកំប៉ុក! ល្មមៗអិសិនទៅ។
កៈ ចា!!
ខៈ អញ្ចឹងឯង។
ខៈ ចា! ហើយបានសិរវត្ថិភាពផ្ទះយើង! គេងយប់ឡើងអី។ ថ្ងៃឡើងអី!
យើងវាស្រួលស្រណុកចិត្តដែលណាស់។
ខៈ ចា!! យើងវាទៅនេះទៅនោះមួយភ្លេចអីបានហាស់។
កៈ វាជួយយការពារផ្ទះហើយមាន់ទាយើងវាច្រើន។
ខៈចា!! ហើយពេលថ្ងៃឡើងយើងបិទទៅយើងមិនភ័យខ្លាចឆ្កែណាវាមកចូល។
កៈ ចាបង!!
ខៈ ចា!! មុនដំបូងវាប្រសែកប្រសាច! ប្រាំប្រាំមួយមិនដឹងថាវាមកពីណាទេ។
ខាំមាន់ខាំទាងាប់អស់។ ចឹងបានថាពិបាកណាស់!
កៈ អញ្ចឹង!
ការងារក្រៅពីស្រែចំការអីបងអត់មានការងារអីធ្វើផ្សេងដែលបងធ្លាប់ធ្វើក្នុងជីវិតរបស់បងពីមុនមកដល់ពេលឥឡូវនេះ?
ខៈ ពីមុនមកអត់មានទេ!! មានតែធ្វើស្រែចំការ។
ហើយមានតែលក់របស់របរពីដើម។ ហេ! កាលពីដឹងក្ដីមកដឹងតែលក់!
ហើយទៅផ្សារលក់អីវ៉ាន់អញ្ចឹង។
កៈ ចាបង!!
ខៈ ចា!! មានស្រែចំការហើយមានគោ! ដល់ពេលមកដល់ឥឡូវនេះវាអញ្ចឹង។ ចា!
កៈ ចា!! អញ្ចឹងបងមានដុងមួយនឹងតាំងពីតូចមកហីបង?
ខៈ ចា!! បើរឿងលក់គឺចំនាញហើយខ្ញុំចា!!
កៈ ចា!! ដោយសាតែមានដុងលក់តាំងពីតូចមក។
ខៈ ចា! ហាហា។
កៈ ចាត្រូវហើយបងអញ្ចឹង។
ខៈ ជីវិតតស៊ូរហត់នឿយណាស់អ្នកគ្រូអើយ។
កៈ ចាបង!!
ខៈ មិនហត់ខ្ជិលទេអ្នកគ្រូ។
កៈ ចាបង!!
ខៈ ជីវិតយើងចេះតែទៅហើយ។ បើយើងតៅលេងរួចយើងមិនឈប់។

កៈ ចា!! នឹងអើយបង។
ខៈ តែបើគេមិន!! គេឃើញយើងងញ្ជឹងគេមិនអរជាមួយយើងទេណាស់។
កៈ ចាបង!!
អញ្ចឹងតើជីវិតរបស់បងកាលពីក្មេងមកដល់ឥឡូវខុសគ្នាយ៉ាងម៉េចដែលទៅបង?
រហូតដល់ធំនេះ! នឹងមានគ្រួសារហើយ?
ខៈ ជីវិតខ្ញុំហាអ្នកគ្រូ!! ពេលយើងអត់ទាន់មានគ្រួសារយើងវាសប្បាយចិត្តជាង!!
កៈ អូ!!! អញ្ចឹងវិញ។
ខៈ ចា!! ខ្ញុំអញ្ចឹងវិញ។ ពេលយើងអត់ទាន់មានគ្រួសារ!
យើងអត់មានភ័យព្រួយខ្លាចរឿងអត់ស៊ីទេណាស់?
កៈ ចាបង!!
ខៈ គ្រួសារយើងគ្រប់គ្រាន់!! មានហូបគ្រាប់គ្រាន់។ វាមិនសូវថាមានបានអីទេ!!
តែយើងវាមិនសូវពិបាកចិត្ត។
ហើយពាក់ឡើងជ្រៀកកាលខ្ញុំនៅជាមួយម្ដាយខ្ញុំហាស់!
កៈ ចាបង!!
ខៈ ហើយមានលុយចាយពេញដៃ។ ហើយមិនខ្វល់ទេ! អ្នកណាមិនលក់!!
អត់មានភ័យខ្លាចថាមានបញ្ហាអីទេឬក៏ពិបាកខ្វល់អីទេ!
កៈ ចាបង!!
ខៈ ពេលដែលយើងមានគ្រួសារយើងមានកូន។
ខ្វល់តើបែងចែកវាគ្រប់មុខហាអ្នកគ្រូ។ ហោកប្ដី! ណាកូន!
ម្ហូបអាហារអោយពួកវាស៊ី។
ឈើជាយប់ប្រលប់ហាស់អីគ្រប់មុខហើយយើងភ័យខ្លាចតែយើងវាជំពាក់គេហាអ្ន
កគ្រូ។ យើងភ័យយើងចេះតែគិតហាស់។
កៈ ចាបង!!
ខៈ ចា!! ដូចថាមិចង់អោយជំពាក់គេទេតែវានៅតែជំពាក់។
កៈ ចា!!
ខៈ អញ្ចឹងបានថាអាបញ្ហាទាំងអស់នឹងវាពិបាកជាងកាលដែលនៅលិវហាស់!៕
កៈ ចាបង!!
ខៈ ចា!! ពិបាកណាស់។ មិនពិបាកលេងៗទេណាស់!
និយាយទៅវាចេះតែនឹកឃើញហើយ។
កៈ ចាបង!!
ខៈ ចា!!
កៈ ដឹងថាពាក្យពិបាកមួយដឹងតែពិបាកហើយ។
ខៈ ចា!! ចង់និយសយថា! គេវាបិបាកមែនតែវាពិបាកកំរិតវាផ្សេងគ្នាហាង្នកគ្រូ។
កៈ ចាបង!!
ខៈ កំរិតគេវាស្រាល។ គេអ្នកខ្លះ! គេពិបាកមែនតែគេដើរគេដើរលេង។
ហើយអ្នកខ្លះគេអត់អីដូចយើងដែលហាស់!
កៈ ចាបង!!
ខៈ គេសប្បាយគេមិនសូវគិតទេ។ គេមកវិញមានអីស៊ីដូចតែយើង។
កៈ ចា!!
ខៈ ហើយយើងនេះវិញមានទព្យរបស់អីដែល។ តែនៅតែហត់នឿយលំបាក។
គេចវាមិនផុត៕
កៈ ចា!! គិចទៀតទៅពេលបានកកូនចំមានការងារធ្វើអស់ទៅជិវិត!
សង្ឃឹមថាវាលេងពិបាកងអញ្ចឹងទៀតហាស់បង។
ខៈ ចា!!
កៈ តើយើងខំទៅជិវិតរបស់យើងនឹរីកចម្រើនហើយមែនទេបង?
ខៈចានឹងហើយ!!
កៈ ណាស់តែយើងខ្ជិល! យើងអត់ចង់ធ្វើអីតើ។

ខៈ ចាវាចឹងឯង!
កៈ ហើយបើយើងដេកចាំតែព្រេងវាសនា។ ព្រេងវាសនាមិនរត់មករកយើងទេ!៕
ខៈ ចា!! យើងជាអ្នករត់ទៅរកវាវិញ។
កៈ ទាល់តែយើងរត់ទៅរកវា! អានឹងទាល់តែយើងនឹខំដែរហាស់។
ខៈ ចា! ហើយខ្ញុំនឹកឃើញអញ្ចឹងដែលហាស់!
កៈ ចា!!
ខៈ ខ្ញុំថាខ្ញុំអត់មានអីរំពឹងទេ។
កៈ ចាបង!!
ខៈ តែគេរំពឹងលក់ស្រែ!!គេរំពឹងហាស់។
កៈ ចាបង!!
ខៈ ចា! ទៅខ្ញុំក៏ថារបស់យើងវាមើលមិនទាន់ឃើញ។
ដីយើងវាពិតមែនតែយើងលក់វាមិនទាន់បាន។ យើងកុំរំពឹងវា។
កៈ ចាបង!!
ខៈ ខំធ្វើអ្វីរាល់ថ្ងៃដែលយើងមើលឃើញនេក។
កៈ ចា!!
ខៈ ខ្ញុំថាចឹង! បើរាល់ថ្ងៃដែលយើងលក់លេងបានចាំយើងគិតទៀតទៅ។
ដល់ថ្ងៃដែលខ្ញុំមានលុយក៏ខ្ញុំឈប់ធកការីរ៉ៃដែល។ តើខ្ញុំហត់ខ្ញុំក៏សំរាកដែលហើយ។
កើ ចាបង!!
ខៈ នេះកំលាំងខ្ញុំនៅធ្វើរួច!
កៈ ចាបង!!
ខៈ ហើយគេថាជោយខ្ញុំ!! យើងនឹងវាខ្វាម។
អត់ចេះយកពេលវេលាខ្លះសំរាកខ្លួនអញ្ចឹងហាស់។ ធ្វើអោយហត់នឿនខ្លួនឯងចា។
ហើយតាំងតែរអ៊ូរថាចេះចុះ។ ចា!
កៈ ចាបង!!
ខៈ ហើយគេថា!!
ខំរាល់ថ្ងៃនឹងដើម្បីនរណា?ហើយខ្ញុំថាខំរាល់ថ្ងៃនឹងមិនដើម្បីអ្នកណាគឺដើម្បីគ្រួសារ
នឹងឯង។ ខ្ញុំមិនយលទៅណារាល់ថ្ងៃនឹងហួរ។ ខ្ញុំខឹង! ខ្ញុំថា។
ខ្ញុំមិនបានខំយកទៅអោយឪពុកម្តាយរបស់ខ្ញុំទេ។
កៈ ចា!!
ខៈ ម៉េចក៨ឯងមិនគិតចឹងខ្លះផង?
កៈ ចា!!
ខៈ ឮយើងនិយាយពាក្យចឹងគេខឹង។
កៈ ចាបង!!
ខៈ គេថាយើងនឹងវាសំដីឡូយដាក់គេ។ សំដីឡូយអី! ខ្ញុំនិយាយវាការពិតអញ្ចឹង។
កៈ ចា!!
ខៈ កើតមកជាមនុស្សហើយណាស់ត្រូវតែតស៊ូ។ កុំពឹងគេ!
កុំពឹងអារបស់ណាដែលមើលមិនឃើញហ្វ។
ពឹងតែអារបស់ណាដែលយើងមើលឃើញរាល់ថ្ងៃនេក។ ដែលយើងខំនេក។
កៈ ចាបង!!
ខៈ អារឿនដីរឿងស្រែ! បើថាយើងចង់លក់វាទៅមុខទៀតតើ។
កៈ ចាបង!!
ខៈ យើងលក់លេងបានចាំគិតទៀតមែនហេអ្នកគ្រូ?
កៈ ចាបង!!
ខៈ ហើយចាំយើងគិតទៀតទៅ យើងខំរកទៅ។យើងរកហើយបើវាមិនមាន!
វាមិនដឹងថាធ្វើម៉េចហះ។ មែនទេអ្នកគ្រូ?
កៈ ចាបង!!
ខៈ យើងខំអោយតែស៊ីគ្រប់ទៅ។

ក៖ ចា!! អញ្ចឹងពេលបងធំឡើងដែលបានលេងសប្បាយអីដែលអត់?
កាលដែលបងធំឡើងនឹងបងមានកែមមានអីលេងនឹងគេដែលអត់?
ខ៖ អត់ដែលមានសោះ។
ក៖ កាលនឹងមានទូរស័ព្ទអីប្រើនឹងគេដែរតើហី?
ខ៖ អត់ដែលទាន់មានទេ។
ក៖ អត់ដែលមានទេបងណោះ?
ខ៖ អ្នកគ្រូចង់និយាយថាជាក់!!! តាំងពីធំដឹងក្ដីមក។ នេកអ្នកគ្រូ!
ទឹមតែពីរឆ្នាំនេះទេដែលខ្ញុំចេះប្រើទូរស័ព្ទហាស់!
ក៖ អូ!!! ចា។
ខ៖ ពេលដែលខ្ញុំលក់អីវ៉ាន់នេះឯង។
ក៖ ចាបង!!
ខ៖ តាំងពីមានដប់១៥ឆ្នាំកន្លងមកខ្ញុំមិនដែលប្រើទូរស័ព្ទទេ។តាំងពីនៅនេះ!
មានតែប្ដីទេ។
ក៖ អូចា!!!
ខ៖ ខ្ញុំអត់ដែលេវីវរទេ។ ខ្ញុំអត់ចេះប្រើខ្ញុំខ្ចិល។
ក៖ ចា!!
ខ៖ ខ្ញុំមិនដឹងថាមានការទាក់ទងទៅអ្នកណា។ ដូចបងប្អូនខ្ញុំអញ្ចឹង!
ខ្ញុំយកតែទូរស័ព្ទឱវាខលទៅទេចា!
ក៖ ចាបង!!
ខ៖ យើងវាមិនដែលប្រើ។ ដល់ពេលពីរឆ្នាំនេះយើងលក់អីទៅ! យើងនឹងឃើញថា។
មួយគេទិញអីចឹងហាស់!៕
ក៖ គេខលមក៕
ខ៖ គេខលទៅ! រកតែប្ដីនៅនេះ។ គេរអ៊ូដាក់យើងហាស់។ រកតែប្ដីនៅនេះ!
រកតែធ្វើការងារអីមិនកើត។ មិនដឹងអាណាំច្រលំលេខមកមិនដឹងអាណាអាណី។
ហើយទៅគេទិញអោយមួយ! អា២០រៀល។ អាតូចនេហ៎! ប្រើអានឹងឯង។
ក៖ ចាបង!!
ខ៖ ចា! ប្រើអានឹងឯងសព្វថ្ងៃហ្ន!!!
ក៖ អាអិនចចពិលនឹងហីបង???
ខ៖ ចា! អានឹងចាប្រើអានឹងឯង។
ក៖ចាបង!!
ខ៖ ចាមួយជីវិតហើយ! តាំងពីធំដឹងក្ដីមក។ ប្រើតែអានឹងឯង។
ក៖ ចា! កាលខ្ញុំនៅខ្ញុំប្រើតែអានឹងដែលតើ។
ខ៖ វាធន់។ រូសអត់បែកទេ។
ក៖ ចា! អានឹងមានកែមលេង!! មានកែមពស់ហ្ន?
ខ៖ ហាហា!! ចានឹងហើយ។ តីតតើតៗហាស់?
ក៖ ចានឹងហើយ។
ខ៖ ចា! អានឹងហើយ។ ខ្ញុំប្រើអានឹងឯង!
មិនដែលមានពេលទៅចុលលេងណាបើមួយថ្ងៃៗរវល់ចង់ដាប់ហើយ។
ក៖ ចា! តែបងឯងធ្លាប់លេងកែមនឹងដែលតើហី?
ខ៖ អត់!! អត់ដែលសោះ។
ក៖ ចឹងថ្ងៃណាមួយសាកលេងទៅ។
ខ៖ ហាហា!!! អ្នកគ្រូអើយរវល់ដល់កំណាត់ហើយ។ រកណាទៅលេង។
ក៖ ចា!! អញ្ចឹងពីក្មេងហាស់! មានម្ហូបណាដែលបងចូលចិត្តញាំជាងគេអត់?
ខ៖ ខ្ញុំហ្ន?
ខក៖ ចា!!
ខ៖ ម្ហូបដែលខ្ញុំចូលចិត្តហី?
ក៖ សម្លរកកគូហីបង?

ខ៖ ខ្ញុំហូបមិនសូវរើសទេ!ហូបបានហាស់!
ក៖ ចង់និយាយថាម្ហូបណាដែលបងចូលចិត្តជាងគេ?
ខ៖ ម្ហូបដែលខ្ញុំចូលចិត្តជាងគេ! សម្លរម្ជូរល្ពុង! បុកព្រិកអីហាស់?
ក៖ ចាបង!!
ខ៖ សំឡមជូរល្ពុងហើយបុកព្រិកខ្ញុំចូលចិត្តណាស់។ វាឆ្ងាញ់ជាងគេហាស់។
ក៖ ចបង!!
ខ៖ បើសំឡដែលខ្ញុំស្អប់ជាហាគេសំឡចខ្ចីស។ ខ្ញុំអត់សូវចុចិត្តទេ។
ក៖ អូ!!!
ខ៖ ខ្ញុំចាញ់ក្លិន។ សំឡខ្ចីសវារដើមៗ។
ក៖ ចា!!
ខ៖ បើសំឡមជូរស្រែយើងដីហតែឆ្ងាញ់ហើយ!
ក៖ មជូរស្រែហ្វ?
ខ៖ ចា!!
ក៖ ជាមួយត្រគួនហីបង?
ខ៖ ជាមួយត្រកួន! ល្ពុងប្រលិតអីនឹងហាស់?
ក៖ ចាបង!!
ខ៖ ចូលចិត្តណាស់។ បុកព្រិក!
ក៖ ចាបង!! អញ្ចឹងតើបងចេះធ្វើម្ហូបតាំងពីមកឬក៏ម៉េច?
ខ៖ កាលដែលខ្ញុំនៅលីវខ្ញុំអត់សូវចេះទេ។ ដល់ពេលដែលខ្ញុំមានគ្រួសារទៅ។
ខ្ញុំនៅជាមួយម៉ែក្មេក! ទៅគាត់បង្រៀនយើង។ យើងអត់សូវចេះទេ!
គៅគាត់ជួយបង្គាប់អោយយើងធ្វើ។ យើងអត់ចេះទេ! ម្ហូបអីខ្ញុំមិនចេះស្លរទេ។
ពេលដេលនៅជាមួយម៉ែក្មេកទៅ។ ចេះដាំបាយដាំអី។
ក៖ អូចាបង!!!
ខ៖ យើងមិនសូវចេះទេ។
ក៖ ចាបង!!
ខ៖ ចេះតែគាក់តិច។សំឡកូគូអីខ្ញុំមិនចេះទេ!!
តែពេលដល់មានគ្រួសារទៅម៉ែក្មេកគាត់បង្រៀនទៅក៨ចេះ។
ចេះទៅចេះតែឆ្នៃទៅណាស់!
ក៖ ចាបង!!!
ខ៖ គាត់ប្រាប់ដាក់មិចអីមិច! ខ្ញុំចេះតែកត់ទុក។
ខ្ញុំកត់ទុកដាក់នៅក្នុងសៀវភៅតើ។
ក៖ ចាបង!!
ខ៖ ដូចថាសំឡមជូរដាក់អីមុនគេ។ ដូចថាទឹកពុះចឹងត្រូវបង់អីមុខគេ?
ហើយខ្ញុំក៏មើលតាមនឹងផងហាស់។
ក៖ ចាបង!!
ខ៖ ដល់ពេលអញ្ចចឹងទៅបានជាខ្ញុំចេះធ្វើម្ហូបដល់សព្វថ្ងៃនេះ។
ក៖ ចាបង!!
ខ៖ សព្វថ្ងៃនេះខ្ញុំខ្លាចតែការី! ដេលខ្ញុំមិនចេះ។ ការីសាឈ្លូមាន់។
សាច់មាន់សាច់អីយើងអត់ចេះ។ តែបើស្រែជម្ហូតាយើងចេះទាំងអស់។
ក៖ អញ្ចឹងបងអត់ចេះស្លរការីទេ?
ខ៖ ការីចេះស្លរហើយ។
ក៖ អូ!! ចេះហើយ?
ខ៖ ចា!!
ក៖ អត់ចេះតែអាសំឡសម័យឥឡូវប្លែកៗអានឹងខ្ញុំមិនចេះទេ។
ក៖ ហាហចា! នឹងហើយម៉ូតសំឡថ្មី។
ខ៖ តែបើយើងសំឡបុរាណអីអានឹងខ្ញុំចេះ។
ក៖ ចា!!

ខ៖ ចេះបានចា!៕
ក៖ អញ្ចឹងតើបងឯងមានចេះច្រៀងចេះអីទេ?
ខ៖ អត់!!
ក៖ អត់ចេះទេ?? ឥឡូវនេះក៏អត់ចេះច្រៀងដែល?
ខ៖ មិនដែលទេ! ហាហា។
ក៖ អញ្ចឹងចេះស្តាប់បទចម្រៀងតែអត់ចេះច្រៀង?
ខ៖ ហាហ!! ស្តាប់ៗតែយើងមនដែលបានយលចិត្តទុកដាក់។
ក៖ ហាហ!!
ខ៖ តែបើបច្រៀងតែឯង! អាចច្រៀងបានចេះតែច្រៀងទៅណាស់។
ក៖ ចាបង!!
ខ៖ ចេះតែបទពីដើម។ បទឥឡូបមិនចេះទេ។
ក៖ ហាហចា។
ខ៖ បទពីដើមស្តាប់ទៅពិរោះណាស់។ ចេះតែស្តាប់ទៅ។
ក៖ ចា!! អញ្ចឹងនៅក្នុងរង់ក្រុមគ្រួសាររបស់បង!
តើមានជីដូបជីតាណាខាងឪពុកម្តាយបងណាដែលគាត់ចេះខាងភ្លេងបុរាណភ្លេងការ! ភ្លេងតន្ត្រីអីមានពួកគាត់ដុងខាងផ្នែកនឹងដេលបង?
ខ៖ ខាងឪពុករបស់ខ្ញុំដូចជាអត់មាន!
ក៖ អត់មានទេបងនេះ?
ខ៖ ចាអត់មាន។ អត់មានណាដុងខាងនឹងទេ។
ក៖ ចាអញ្ចឹង។ តើផ្ទះដែលបងរស់នៅនឹងហាស់!
ផ្ទះដែលបងនៅពីតូចនឹងហាស់ជាមួយគ្រួសារបងហាស់ផ្ទះមិចដែល?
ខ៖ ធមគួរសម!
ក៖ ធំទូលាយ? ឬក៏សមរម្យមិចដែល?
ខ៖ វា! គ្រួសារខ្ញុំនៅពីដើម។ វាសមរម្យវាទូលាយចា!
ក៖ ចាបង!!
ខ៖ ចា! គ្រួសារខ្ញុំអត់អីទេ។ អត់ដែលមានបញ្ហាអីទេ។
ក៖ ចា!! ជីវភាពអត់ក្រពេកអត់មានពេក?
ខ៖ ចា!! អត់ក្រ។ អត់មានពេកទេចា។
ក៖ ចាមធ្យមចឹង?
ខ៖ ចា! មធ្យមចា។ ដូចយើងចឹងហាស់វាមធ្យម។
ដូចថាយើងរស់នៅស្រុកស្រែចឹងហាស់ម្ហូបវាឆ្ងាញ់។
ក៖ ចាបង!!
ខ៖ ចា!! យើងចេះតែ!! ល់ពេលគេអ្នកក្រុងគេចេះតែហូបឆ្ងាញ់ទៅ។
ដល់ពេលយើងអ្នកស្រុកស្រែមជូរប្រហើរៗនឹង។
ក៖ ចាបង!!
ខ៖ហាហា!
ក៖ អញ្ចឹងផ្ទះនឹងសាងសង់មក! យ៉ាងមិច?
ឪបុលម្តាយក្រុមគ្រួសារជួលគ្នាធ្វើឬក៏យ៉ាងមិចគេធ្វើអោយ?
ខ៖ ចា! ឪពុកម្តាយ។
ក៖ ចា!!
ខ៖ ឪពុកម្តាយ! ស្នាដៃរបស់ពួកគាត់ផ្ទាល់ហា។
អត់មានអាពតណាមកធ្វើអោយទេ។ រួមកំលាំងបងប្អូនគាត់ហាស់?។
ក៖ ចាបង!!
ខ៖ ហើយដល់ពេលដែលគាត់ផ្សំលុយបានទៅគាត់ទៅទិញក្តារ។
ទិញឈើទុកទៅទិញសសរទុកទៅ។ ហើយជួលជាងកមធ្វើអោយខ្លះទៅ!
ក៖ ចា!!
ខ៖ គាត់ធ្វើស្រែសម័យនឹងហាស់។

កៈ ចាបង!!
ខៈ គាត់ធ្វើស្រែលក់ស្រូវបានចឹងទៅ។ គាត់ទិញជាក្តារជាឈើ! យកទិកមកធ្វើផ្ទះ។
កៈ ចាបង!!
ខ ដល់ពេលសម័យឥឡូវ! យើងធ្វើដូចពួកគាត់វាមិនបាមទេអ្នកគ្រូ។
កៈ ចាបង!!
ខៈ រកតែសុីនឹងវាមិនគ្រប់ផង។
កៈ អញ្ចឹង! ផ្ទះកាលពីជំនាន់នឹងធ្វើមកឈើហីបង? ហើយនឹងស្លឹកដូងហី?
ខៈ ធ្វើមកពីឈើសុទ្ធ។
កៈ ហើយនឹងស្លឹកដូងហីកាលណឹង?
ខៈ ពីដើមនឹង! ផ្ទះធ្វើមកពីឈើទាំងអស់។
កើ អូចា!!
ខៈ ដល់ពេលអាពតវារើហាស់។
កៈចាបង!!
ខៈ ហើយដល់ពេលយើងមកវាអត់មានអីបក់!! វាអស់អញ្ចចឹងទៅ។ម៉ែ!!
ចុះបើវាអស់ហើយហូ?
កៈ ចាបង!!
ខៈ ម៉ែគាត់ទៅកាប់ឡូះអាចាងដូងនឹងមកតលបាញដូវស្បូវអញ្ចចឹង។
កៈ ចាបង!!
ខៈ យកមកត្បាញធំៗហើយបាំងដូចស្បូវមក។
កៈ ចាបង!!
ខៈ តែពីដើមគាត់ថាឈើទាំងអស់។ ហើយសុទ្ធតែជាឈើល្អទៀតណាស់។
កៈ ចា!!
ខៈ ឈើឡើងខ្មៅរលោងហាអ្នកគ្រូ។
កៈ អញ្ចឹងជីដូនជីតារបស់បងពួកគាត់ចេះធ្វើចឹងស្រាប់មកបាដោយហីបង???
ចេះធ្វើផ្ទះហាស់។
ខៈ ចុះឮស្តូម៉ែខ្ញុំថា។ ពុករបស់ខ្ញុំពីដើមគាត់ជាងតើ។
កៈ អូជាងផ្ទះ!
ខៈ ចា!!តាខាងម្តាយរបស់ខ្ញុំនឹងហាស់។
កៈ ចា!!
ខៈ ពីដើមឡើយគាត់ជាងតើ។
កៈ ចា!!
ខៈ អញ្ចឹងផ្ទះរបស់បងឯងដឹងតែស្អាតហើយចឹង។
ខៈតែឪពុកខាងខ្សែពុករបស់ខ្ញុំហាស់។
កៈ ចា!!
ខៈ ពីដើម! គាត់ជាអ្នកមានស្រុកស្រែ។ យាយយឺបតាយ៉ម!
គាត់ជាអ្នកមានស្រុកស្រែ។ ផ្ទះរបស់គាត់ធំណាស់ៗ
កៈ ចា!!
ខៈ ពួកគត់មននឹងស្រែនឹងឯង។ បើយើងពីដើមគេថា!! អ្នកមានស្រុកស្រែ។
កៈ ចា!!
ខៈ អញ្ចឹងមាននៃថា! ចំនាញនៅក្នុងគ្រួសាររបស់បងគឺធ្វើស្រែនោះ?
ខៈ ចា!! ជំនាញធ្វើស្រែចំការចា។
កៈ ធ្វើស្រែចំការ!!!
ខៈ បើគាត់មានគឺមាននឹងស្រែនឹងឯងចា!
កៈ ចា!!
ខៈ ធ្វើផ្ទះអីនឹង។ ហើយចិញ្ចឹមកូនចិញ្ចឹមចៅអីមកហា?
កៈ ហើយជំនាញធ្វើផ្ទះក៏ពួកគាត់មានដែល?
ខៈ ចា! តាខ្ញុំគាត់ធ្វើជាងឮពុកម៉ែខ្ញុំគាត់និយាយហាស់។

កៈ ចា!!
ខៈ ចាផាងពីដើម! តែផាងធ្វើតែឈើទេ!
បើជាំសម័យនេះគាត់មិនចេះទេ។ពួកគាត់ខូចអស់ហើយហាស់។
កៈ ចា!!
ខៈគាត់ធ្វើតែឈើបុរាណ។
កៈ ចា!! អញ្ចឹងឥឡូវសួរពីបញ្ហាប្រឈមមុខម្តងទៀតហាស់។
ខៈ ចា!!
កៈ
តើពេលវេលាដែលលំបាកជាំងគេនៅក្នុងជីវិតរបស់បងនៅពេលណា?ហើយបងបានឆ្លងកាត់អាបញ្ហាលំបាកទាំងអស់នឹងដោយបានដោយរបៀបណាដែលតើមានទេ? លំបាកជាងគេដែលបងគិតថាពិបាកនៅក្នុងជីវិតបងហាស់។
ខៈ លំបាកជាងគេ។លំបាករលំបកហលយតែចិត្តយើងនៅតែតស៊ូ។
លំបាកវាលំបាកហាណាស់។
កៈ ចា!!
ខៈ តែយើងត្រូវតែតស៊ូយកជំនេះវាអោយបាន។
កៈ ចា!
ខៈ បើយើងមិនធ្វើ។ យើងខ្ជិល! យើងនឹងឈប់ត្រឹមនឹងហាស់។
កៈ ចា!
ខៈ ហើយបើងឈប់យើងនឹងអត់បានអីទេ។
កៈ ចា!!
ខៈ បើសិនជាយើងចង់បានអ្វីមួយ!យើងត្រូវតែប្តូរហាស់។
កៈ ចា!!
ខៈ ទាល់ទេយើងព្យាយាមបានបានសំរេច!
តែបើយើងធ្វើទុកហើយចឹងបានចេះតែប្តូរធ្វើទាំងយប់ទាំងថ្ងៃហាស់។
កៈ ចា!!
ខៈ ពិបាកគិតនេះ! គិតនោះផង។
ពិបាកគិតណាមួយគ្រួសារយើងមិនពេញចិត្តអោយធ្វើនឹងទេ។
តែយើងពេញចិត្តធ្វើ! យើងត្រូវតែធ្វើវា។
កៈ ចាបង!!
ខៈ យើងត្រូវយកឈ្នះវាអោយបាន។ យើងធ្វើបានចា!
កៈ ចា!!
ខៈ សព្វថ្ងៃនេះក៏យយើងអាចធ្វើបានដែល។ យើងអចយកឈ្នះវាបាន។
កៈ ចា!!
ខៈ យើងអត់ចាញ់ទេ។ នោះបីជាលំបាក!!
ព្រោះអីអាការលំបាកយើងបានឆ្លងកាត់វាមកហើយ។
កៈចា!
ខៈ វាហត់នឿយមកឆ្អែតទោហើយ។ ប៉ុននឹងវាមិនធ្ងន់ទេ។
កៈ ចា!!
ខៈ យើងត្រូវគិតថាទៅមុខយើងត្រូវពិបាកជាងនឹងទៀត។
មិនមែនប៉ុននឹងយើងថាលំបាកទេ។
កៈ ចា!!
ខៈវានៅមានទៀត! វ័យប៉ុនណេះវាមិនទាន់ហួសទេ។ វាមិនទាន់អស់!
កៈ ចា!! ឥឡូវសួរអាលំបាកហើយ! សួរអាសប្បាយវិញម្តង។
ខៈ ចា!
កៈ
ចឹងតើបងមានពេលវេលាណាំដែលបងវងចជាងគេពេលដែលរីករាយក្នុងជីវិតហាស់មានអត់?

ខ៖ អត់ដែលទាន់មានទេ។
ក៖ ចុះបងជាសមាជិកនៅក្នុងព្រះវិហារដែលមែនហេ?
ខ៖ ចា!!
ក៖ ចឹងតើបងចូលព្រះវិហារបងឯងមានអារម្មណ៍មិចដែល?
ខ៖ ពេលចូលព្រះវិហារ!ខ្ញុមមានអារម្មណ៍អានឹងយើងថ្ងៃអាទិត្យហាស់។
ក៖ ចាបង!!
ខ៖ អាំនឹងខ្ញុំមានអាគម្មរណ៍ថាប្បាយ។ យើងឃើញគេ! គេឃើញយើង។
ក៖ នឹងហើយ។
ខ៖ បើយើងមកវិញយើងត្រូវគិតទៀតហើយចា។
ក៖ ចា!!
ខ៖ គិតអាពីរឿងគ្រួសារវិញចឹងហាស់។
ក៖ ចា!!
ខ៖ ពេលដែលយើងទៅព្រះវិហារយើងសប្បាយ!
បាត់អារឿងដែលលំបាកនឹងមួយរយ:មែន។
កើ ចាបង!!
ខ៖ ចា!! ទៅទៅនិយាយពីនេះពីនោះទៅ។ អារឿងដែពិបាកនឹកវាអត់សូវឃើញ។
ក៖ ចា!
ខ៖ ពេលខ្ញុំតៅហាស់!
ក៖ចា!!
ខ៖ លពេលអត់បានទៅព្រហវិហារចឹងវារៀងស្លុកចិត្តហាស់។
ក៖ ចា!
ខ៖ រកទៅលេងព្រះវិហារឯណាបើគេបិទអស់ហើយ។
ក៖ ចានឹងហើយកូវីត។ ចា! នឹងសង្ឃឹមថាគេនឹងបើកមកវិញឆឆាប់ៗបង!!
ខ៖ ចា!!
ក៖ បន្តអធិដ្ឋានមានសេចក្ដីជំនឿទាំងអស់គ្នាទៅ។
ខ៖ ចា!
ក៖ នឹងហើយបង!
បងឯងមានអីប្រាប់មកខ្ញុំទៀតដែលអត់?ខ្ញុំដូចជាអស់អីសួរដែលហើយ!។
ខ៖ អស់ហើយអ្នកគ្រូ!ប្រាប់អស់ហើយ!
ខ្ញុំនិយាយប្រាប់ទាំងប៉ុនមាណសុទ្ធតែជាការពិត។
ក៖ ចាបង!
ចឹងខ្ញុំសូមអរគុណបងច្រើនសំរាប់ការចំណាយពេលលេលាដ៏មានតំម្លៃអោយខ្ញុំធ្វើ
ការសម្ភាសន៏ថ្ងៃនេះ!
ខ៖ ចាអត់អត់អីទេ។
ក៖ ចឹងពីមុននឹងបញ្ចប់តើខ្ញុំសូមថតរូបបងមួយបានអត់?
ខ៖ អត់អីទេ! ថតទៅ។
ក៖ ចា!! អរគុណប្រេីនបង។